ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
<u>លេខ ១៦៦ "ខ១" ក្រ៨</u>
ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២
សំណុំរឿងព្រហ្មទណ្ឌ
លេខ ២៨៨២
ចុះថ្ងៃ២៣ ខែកក្កដា ឆ្នាំ២០២១
សំណុំរឿងស៊ើបសួរ
លេខ ២២០៥
ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១
ដីកាដំណោះស្រាយ
លេខ ៧៦៧
ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២២

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**
បានបើកសវនាការជាសាធារណៈនាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២
វេលាម៉ោង ០២ និង ៣០ នាទី រសៀល សាលសវនាការទី៤ ជាន់ទី១
ដោយមានសមាសភាពដូចខាងក្រោម៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃសាលាដំបូងរាជធានីភ្នំពេញ
លោក [redacted] ចៅក្រមប្រឹក្សានៃសាលាដំបូងរាជធានីភ្នំពេញ
លោក [redacted] ចៅក្រមប្រឹក្សានៃសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២៨៨២ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖**

១-ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ ៣៧ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកម្មកររយាមឡាន ទីកន្លែងកំណើតសង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃុំខ្លួន [redacted] បេតុង ភូមិក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្ដាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ [redacted] មានកូន ០១នាក់ កម្រិតវប្បធម៌ថ្នាក់ទី ១២ ជាទីតាំងជន ទោសពីមុនគ្មាន ។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥១៧១ "ឆ១" ដ.ឃ.ដ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១)

ជាប់ចោទពីបទ **រក្សាទុក ដឹកជញ្ជូន និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទសម្អាតប្រាក់** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤០ មាត្រា៧០ និងមាត្រា៧១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ឈ្មោះ [redacted] ពន្លក ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរជួសជុលម៉ូតូ ទីកន្លែងកំណើត និងទីលំនៅមុនពេលឃុំខ្លួនស្នាក់ [redacted] ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ឪពុកឈ្មោះ [redacted] "ស្លាប់" ម្ដាយឈ្មោះ [redacted] "រស់" លែងលះ មានកូនចំនួន ០១នាក់ កម្រិតវប្បធម៌ថ្នាក់ទី ០៧ ជាទីតាំងជន ទោសពីមុនគ្មាន ។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥១៧០ "ឆ១" ដ.ឃ.ដ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០២១)

ជាប់ចោទពីបទ **រក្សាទុក និង ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន និងបទសម្អាតប្រាក់** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ មាត្រា ៧០ និងមាត្រា ៧១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

៣-ឈ្មោះ[redacted]សួស្តី ហៅ តៅ ភេទប្រុស កើតឆ្នាំ១៩៨២ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅ[redacted]នៃមណ្ឌលអប់រំកែប្រែទី ១ ឪពុកឈ្មោះ [redacted] "ស្លាប់" ម្តាយឈ្មោះ [redacted] "រស់" ប្រពន្ធឈ្មោះ[redacted] "លែងលះ" មានកូនចំនួន ០៣នាក់ កម្រិតវប្បធម៌ថ្នាក់ទី ១២ ជាទីតិជន ទោសពីមុនមាន (បទ ប្លន់សម្លាប់ ផ្តន្ទាទោសអស់មួយជីវិត) ។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៥១៧២ "អ១" ង.ឃ.ង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១)

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ លោក [redacted]រ៉េ អត្តលេខ ១០៣០ មានការិយាល័យនៅផ្ទះលេខ០៧E0 ផ្លូវលេខ១៧៤ (ឧកញ៉ាកេត) សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]ពិសិដ្ឋ ។

មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ លោក [redacted]ឡុងឌី អត្តលេខ ១១២៨ ការិយាល័យនៅផ្ទះលេខ០០២ ផ្លូវលេខ២០២ សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោ[redacted]ពន្លក និងឈ្មោះ[redacted]សួស្តី (លិខិតចាត់តាំងលេខ ១៩៤ /ប្រ.គម/ភព/២២ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា) ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីអំឡុងឆ្នាំ២០១៤ ឈ្មោះ [redacted]ពិសិដ្ឋ បានរកស៊ីជួញដូរគ្រឿងញៀន និងដឹកជញ្ជូនគ្រឿងញៀនឱ្យម៉ូយ តាមការបញ្ជារបស់ឈ្មោះ[redacted]Kali (ឈ្មោះក្នុងហ្វេសប៊ុក) បានចំនួន ០៤ លើក ដោយទទួលបានកម្រៃជើងសារក្នុង ០១ គីឡូ តម្លៃ ១០០ដុល្លារអាមេរិក ។ ឈ្មោះ[redacted] ពិសិដ្ឋ ក៏បានទិញគ្រឿងញៀនពីឈ្មោះ [redacted]Kali បានចំនួនប្រហែល ០៤ លើក តាមរយៈលេខទូរស័ព្ទ ០៨៧ ៨១០ ៥១៥ ដើម្បីលក់បន្តទៅឱ្យម៉ូយ ។ ចំពោះប្រាក់ដែលបានពីការលក់ និងដឹកជញ្ជូនគ្រឿងញៀនឱ្យម៉ូយនោះ ឈ្មោះ[redacted]ពិសិដ្ឋ បានយកទៅទិញដីឡូត៍លេខD2 ទំហំ 70m² ស្ថិតនៅភូមិជាងទង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដូចមានក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ២៥៤១ លបកព្រ. ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់អភិបាលខណ្ឌសែនសុខ និងទិញម៉ូតូមួយគ្រឿងម៉ាក HONDA PCX 150 ពណ៌ស ស្លាកលេខ ស្វាយរៀង 1P-9730 ។ លុះនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ [redacted] Kali បានទំនាក់ទំនងមកឈ្មោះ [redacted] ពិសិដ្ឋ ឱ្យចាំយកគ្រឿងញៀនដែលគេបានផ្ញើមកឱ្យម៉ូយដូចរាល់ដង ។ បន្ទាប់មកឈ្មោះ [redacted] ពិសិដ្ឋ ក៏បានចាំយកគ្រឿងញៀននៅចំណុចដីឡូត៍ទុកចោល ក៏ត្រូវសមត្ថកិច្ចត្រួតពិនិត្យឆែកឆេរឃើញមានថ្នាំញៀនមួយចំនួន ។ គាប់ជួនឈ្មោះ[redacted]ពន្លក ក៏ទំនាក់ទំនងមកឈ្មោះ [redacted] ពិសិដ្ឋ ថាខ្លួនបានយកឥវ៉ាន់មកឱ្យតាមរយៈឈ្មោះ[redacted]សួស្តី ហៅ តៅ ជាអ្នកឱ្យយកមកដោយបានណាត់ជួបគ្នាយកគ្រឿងញៀនទៅម៉ូឆែន៥ ។ ឈ្មោះ[redacted] ពន្លក បានជិះឡានម៉ាក TOYOTA CAMRY 150 ពណ៌ខ្មៅ ស្លាកលេខ 2T-6441 ដឹកបារចំនួន ៣ មកដល់គោលដៅណាត់ជួប ក៏ត្រូវមានសមត្ថកិច្ចត្រួតពិនិត្យ រកឃើញបារចំនួន ០៣ (ដែលក្នុងបារនោះមានត្រីងៀត ដោយបង្កប់គ្រឿងញៀនក្នុងនោះផងដែរ) ។ បន្ទាប់មកសមត្ថកិច្ចបានធ្វើការឃាត់ខ្លួន និងដកហូតវត្ថុតាងរួមមាន៖ ១-ហិបដែកចំនួន ០១ ពណ៌ទឹកប្រាក់ ដែលមានកំណត់ហេតុបិទកេសដែកដាក់វត្ថុតាង លេខ ២៣១ កណហ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ ដោយមានស្នាមមេដៃស្តាំ ឈ្មោះ[redacted] ពិសិដ្ឋ និងឈ្មោះ [redacted] ពន្លក និងហត្ថលេខាគណៈកម្មការ ដោយកំណត់ហេតុបញ្ជាក់ថាវត្ថុតាងដកហូតបានបីគោលដៅ ។ គោលដៅទី១ ក្រោមពណ៌សថ្លាទម្ងន់ ១០០



Scanned with CamScanner

(មួយរយ) ក្រាម (មេតំហ្វេតាមីន) ជារបស់ឈ្មោះ [redacted] ពិសិដ្ឋ ។ គោលដៅទី២ ជារបស់ឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted]ន្លក មាន៖ ក-ក្រាមពណ៌សថ្លាទម្ងន់សរុប ២៩៩៤០ (ពីរម៉ឺន ប្រាំបួនពាន់ ប្រាំបួនរយ សែសិប) ក្រាម តែបានដកទម្ងន់ ២២.៤៧ (ម្ភៃពីរ កណ្ដាក់សញ្ញា សែសិបប្រាំពីរ) ក្រាម ជូនទៅក្រុមការងារចំពោះកិច្ច ។ ខ-ក្រាមពណ៌ស ទម្ងន់សរុប ១៩៩៤៦.៦៦ (មួយម៉ឺន ប្រាំបួនពាន់ ប្រាំបួនរយ សែសិប ប្រាំមួយ កណ្ដាក់សញ្ញា ហុកសិបប្រាំមួយ) ក្រាម តែបានដកទម្ងន់ ៦៦.៩២ (ហុកសិបប្រាំមួយ កណ្ដាក់សញ្ញា កៅសិបពីរ) ក្រាម ជូនទៅក្រុមការងារចំពោះកិច្ច ។ គោលដៅទី៣ ក្រាមពណ៌សថ្លាទម្ងន់ ៣០០ (បីរយ) ក្រាម (មេតំហ្វេតាមីន) ជារបស់ឈ្មោះ [redacted] ពិសិដ្ឋ ។ តាមកំណត់ហេតុខាងលើនេះ ឃើញថាសមត្ថកិច្ចក៏បានដកហូតនូវវត្ថុតាង និងសម្ភារៈមួយចំនួនទៀត ។ តាមចម្លើយសារភាពរបស់ឈ្មោះ [redacted] ពិសិដ្ឋ បង្ហាញថា ឈ្មោះ [redacted] ពិសិដ្ឋ បានរកស៊ីលក់ដូរថ្នាំញៀនតាំងពីអំឡុងឆ្នាំ២០១៤ ហើយចំពោះប្រាក់ដែលបានមកពីការលក់គ្រឿងញៀនបានយកទៅទិញដីឡូតិ៍លេខD2 ទំហំ70 ម៉ែត្រការេ ទីតាំងស្ថិតនៅភូមិជាងទង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដូចមានក្នុងលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែង លេខ ២៥៤១ លប.កព្រ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់អភិបាលខណ្ឌសែនសុខ និងទិញម៉ូតូ ០១ គ្រឿងម៉ាក HONDA PCX 150 ពណ៌ស ស្លាកលេខ ស្វាយរៀង 1P-9730 ចំណែកប្រាក់នៅសល់បានចំណាយផ្គត់ផ្គង់ក្នុងជីវភាពគ្រួសារ ។ ឈ្មោះ [redacted] ពិសិដ្ឋ ក៏បានទទួលស្គាល់ផងដែរថា ខ្លួនបានដឹកគ្រឿងញៀនយកទៅឱ្យម៉ូយតាមបញ្ជារបស់ឈ្មោះ [redacted] Kali (ឈ្មោះក្នុងហ្វេសប៊ុក) បានចំនួន ០៤ លើក ។ តាមចម្លើយរបស់ឈ្មោះ [redacted]ពន្លក ក៏បានបង្ហាញផងដែរថា កាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ[redacted]ពន្លក បានដឹកបាវចំនួន ០៣ ដែលក្នុងនោះមានត្រីងៀតបង្កប់គ្រឿងញៀនពីខាងក្នុងទៅឱ្យឈ្មោះ [redacted] ពិសិដ្ឋ នៅម្តុំម៉ូដែន៥ តាមការបញ្ជារបស់ឈ្មោះ[redacted]សួស្តី ហៅពៅ ។ ចំពោះកម្រៃដែលបានពីការដឹកជញ្ជូនថ្នាំញៀននោះ គេបានយកទៅទិញឡានមួយគ្រឿងម៉ាក TOYOTA CAMRY 150 ពណ៌ខ្មៅ ស្លាកលេខ 2T-6441 ។ បន្ទាប់ពីធ្វើការសាកសួរសមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកកាន់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៦៩៨ អ.យ.ត ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១០២១ "ហ" ជ.ដ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២។

**នាពេលសវនាការ**

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយនៅតំណាក់កាលសមត្ថកិច្ចថា ៖ ខ្លួនបានចាប់ផ្តើមរកស៊ីដឹកជញ្ជូន និងជួញដូរគ្រឿងញៀន ចាប់ពីអំឡុងពាក់កណ្ដាលឆ្នាំ២០២០ ។ ក្នុងមួយខែខ្លួនទទួលបានការងារធ្វើ ០២ ឬ ០៣ លើក ដោយក្នុងមួយលើកៗ មានគ្រឿងញៀនប្រហែល ០៣ ដុំ ទៅ ០៤ ដុំ និងយកទៅទម្លាក់ឱ្យម៉ូយអ្នកមកទទួល ។ បន្ទាប់ពីប្រគល់គ្រឿងញៀនរួចរាល់ទើបម្ចាស់លេខ [redacted] វេរលុយតាមវីងឱ្យកម្រៃថ្លៃដឹកជញ្ជូន ។ ចាប់តាំងពីទទួលបានការដឹកជញ្ជូនគ្រឿងញៀនមក នៅអំឡុងដើមខែមករា ឆ្នាំ២០២១ ខ្លួនបានទទួលការងារដឹកជញ្ជូនគ្រឿងញៀនចំនួន ១២ ដុំ មួយលើក និងបានយកទៅបកសំបកកញ្ចប់តែ និងថង់ប្លាស្ទិកខាងក្នុងចេញ ដោយទុកថង់ជ័រប្លាស្ទិកដែលស្អិតជាប់នឹងគ្រឿងញៀន រួចទើបរុំនឹងខោអាវជជុះរៀបចំដាក់ចូលក្នុងប្រអប់កេសស្មោរពីរផ្សេងគ្នាដែលមួយប្រអប់មាន ៥ ដុំ និងមួយប្រអប់ទៀត ៧ ដុំ ដើម្បីរង់ចាំម្ចាស់លេខ [redacted] ផ្ញើសារលេខទូរស័ព្ទអ្នកមកទទួលគ្រឿងញៀន ។ បន្ទាប់ពីផ្ញើដល់ដៃអ្នកទទួលគ្រឿងញៀនរួច ទើបម្ចាស់លេខ ០៩៦ [redacted] វេរលុយចំនួន ១.២០០ ដុល្លារអាមេរិក តាមរយៈវីង ។ ចំណែកឯលុយដែលបានមកពីកម្រៃដឹកជញ្ជូន និងជួញដូរគ្រឿងញៀន ខ្លួនបានយកទៅទិញដីមួយកន្លែង និងសង់ផ្ទះនៅក្នុងសង្កាត់ក្រាំងធ្នង់ និងមួយចំនួនបានទិញម៉ូតូ និងផ្គត់ផ្គង់ប្រពន្ធខ្លួនចំនួន ៣ នាក់ នៅខេត្តសៀមរាប និងមួយចំនួនទៀតទុកសម្រាប់ចាយវាយ ។ រាល់គ្រឿងញៀន

ដែលទទួលបានពីរថយន្តតាក់ស៊ីដែលគេបានផ្ញើមក គឺខ្លួនបានយកចូលមកក្នុងដីឡូតិ៍ រួចហើយវេចខ្ចប់ឡើងវិញមុនពេលដឹកជញ្ជូនយកទៅប្រគល់ឱ្យម៉ូយបន្ត ។ នៅក្នុងកញ្ចប់គ្រឿងញៀនទីមួយៗដែលគេផ្ញើមកមានភិនភាគពណ៌ខុសៗគ្នា និងមានអក្សរលើកញ្ចប់ថង់ប្លាស្ទិកពណ៌សជាអក្សរចិន AAA, BB ជាដើម ។ ចំណែកឯគ្រឿងញៀនចំនួន ០៣ កញ្ចប់ ដែលសមត្ថកិច្ចបានដកហូតនៅដីឡូតិ៍កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ វាគឺជាគ្រឿងញៀនម៉ាទឹកកកដែលខ្លួនបានទិញពីម្ចាស់លេខទូរស័ព្ទ[redacted]៨១០ ៥១៥ កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ចំនួនកន្លះគីឡូក្រាមក្នុងតម្លៃ ៣.៥០០ ដុល្លារអាមេរិក ។ មុនពេលទិញគ្រឿងញៀនអ្នកលក់តម្រូវឱ្យវេរលុយទៅលេខ [redacted]៣៧២ ជាមុន លុះបានប្រហែលកន្លះម៉ោងក្រោយទើបគេណាត់ឱ្យទៅទទួលគ្រឿងញៀននៅម្តុំក្រោយមន្ទីរពេទ្យកាល់ម៉ែត្រ ។ នៅក្នុងឆ្នាំ២០២០ មិត្តភ័ក្តិខ្លួនបានណែនាំឱ្យស្គាល់ទណ្ឌិតស្រីម្នាក់ឈ្មោះ [redacted] Kali (ឈ្មោះហ្វេសប៊ុក) នៅមណ្ឌលអប់រំកែប្រែ ម២ ។ ក្នុងអំឡុងចូលឆ្នាំខ្មែរ ខ្លួនបានទំនាក់ទំនងទៅឈ្មោះ[redacted] Kali ដើម្បីរកទិញគ្រឿងញៀនម៉ាទឹកកកដើម្បីទុកលក់បន្តហើយឈ្មោះ Na Kali បានឱ្យលេខទូរស័ព្ទលេខ ០៨៧ ៨១០ ៥១៥ ដើម្បីទំនាក់ទំនងទិញគ្រឿងញៀនទុកសម្រាប់លក់រាយ ។ ក្នុងមួយខែខ្លួនទិញគ្រឿងញៀនពីអ្នកលក់មានលេខទូរស័ព្ទខាងលើ ប្រហែល ០៤ លើក ដោយក្នុងមួយលើកៗខ្លួនបញ្ជាទិញគ្រឿងញៀនចំនួន ១០០ ក្រាម ក្នុងតម្លៃ ៧០០ ដុល្លារ និងលក់ទៅវិញបាន ៨០០ ដុល្លារ សម្រាប់ការលក់ដុំ និងបានប្រហែល ១.០០០ ដុល្លារអាមេរិក សម្រាប់លក់រាយ ។ ជាក់ស្តែងនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ ២០២១ មានម៉ូយរកទិញគ្រឿងញៀនចំនួន ១០០ ក្រាម នៅវេលាម៉ោងប្រហែលជាង ១៨ ខ្លួនក៏បានទាក់ទងទៅលេខ [redacted]៨១០ ៥១៥ ដើម្បីទិញគ្រឿងញៀន ហើយបានណាត់ទីតាំងសម្រាប់ធ្វើការដោះដូរ ។ បន្ទាប់ពីវេរលុយតាមវីងទៅលេខទូរស័ព្ទខាងលើ ប្រហែលជា ២០ នាទីក្រោយ ក៏មានមនុស្សប្រុសម្នាក់មានអាយុប្រហែលជាង ២០ឆ្នាំ ជិះម៉ូតូម៉ាកស្កុបពីពណ៌ខ្មៅយកគ្រឿងញៀន មកប្រគល់ឱ្យនៅផ្លូវបេតុងច្រមុះជ្រូកមន្ទីរពេទ្យកាល់ម៉ែត ។ រហូតមកដល់អំឡុងឆ្នាំ២០២១ ឈ្មោះ [redacted]Kali ក៏បានដាក់ការងារឱ្យខ្លួនធ្វើ (ការងារដឹកជញ្ជូនគ្រឿងញៀន) ដោយខ្លួនបានធ្វើការដឹកជញ្ជូនគ្រឿងញៀនឱ្យឈ្មោះ [redacted] Kali បានចំនួន ០៤ លើក ។ ក្នុងមួយលើកៗដឹកជញ្ជូនគ្រឿងញៀនចំនួន ០៣ គីឡូក្រាមយកទៅឱ្យអ្នកមកទទួលបន្តផ្សេងៗគ្នា និងទីតាំងផ្សេងៗគ្នា ក្នុងរាជធានីភ្នំពេញ ដោយទទួលបានប្រាក់កម្រៃ ១០០ ដុល្លារ ក្នុង ១ គីឡូក្រាម ។ លើកទី១ ក្នុងអំឡុងពាក់កណ្តាលខែមិថុនា ឆ្នាំ២០២១ ឈ្មោះ[redacted]Kali ដែលប្រើប្រាស់លេខ[redacted]៨៥៦៤ បានឱ្យខ្លួនដឹកជញ្ជូនគ្រឿងញៀនចំនួន ២ គីឡូក្រាម ដោយមានលាយត្រីងៀត ផ្អក និងប្រហុកចំនួន ៣ ប្រអប់ដោយខ្លួនទទួលគ្រឿងញៀនពីឡានតាក់ស៊ីម៉ាកសាំយ៉ុង នៅម្តុំក្រោយ Grand Phnom Penh នៅម៉ោងប្រហែលជាង ១២ រសៀល រួចយកទៅប្រគល់ឱ្យបុរសម្នាក់អាយុប្រហែលជាង ៣០ឆ្នាំ ជិះម៉ូតូមិនស្គាល់ម៉ាកនៅម្តុំរង្វង់មូលកាំកូស៊ីធី ។ នៅវេលាម៉ោងប្រហែលជាង ១៨ បន្ទាប់ពីប្រគល់គ្រឿងញៀន ២ ដុំនោះបានប្រហែលជាពីរម៉ោងក្រោយឈ្មោះ[redacted] Kali បានឱ្យគេវេរលុយមកខ្លួនចំនួន ២០០ ដុល្លារ ជាថ្នូរថ្លៃដឹកជញ្ជូន ។ លើកទី២ ក្នុងអំឡុងដើមខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ៨ ព្រឹក តាមការបញ្ជាពីឈ្មោះ Na Kali ខ្លួនបានទៅទទួលគ្រឿងញៀនចំនួន ៣ ដុំ មានលាយត្រីងៀត ផ្អក និង ប្រហុកចំនួន ៣ ប្រអប់ ពីបុរសម្នាក់បើកឡានម៉ាកព្រូសពណ៌ឈាមជ្រូកមិនចាំស្លាកលេខ នៅចំណុចផ្លូវជាសុផារ៉ា ជិតស្ថានីយ៍សាំងភីធីធី ខណ្ឌឬស្សីកែវ ហើយប្រគល់ឱ្យមនុស្សប្រុសម្នាក់ទៀតមិនស្គាល់ឈ្មោះ នៅចំណុចជិតរង់តែនទួលគោក ។ ខ្លួនទទួលបានប្រាក់ចំនួន ៣០០ ដុល្លារ ជាកម្រៃជើងសារបន្ទាប់ពីចប់ការងារ ។ លើកទី៣ នៅអំឡុងថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ[redacted] Kali បានឱ្យខ្លួនយកគ្រឿងញៀនចំនួន ៣ ដុំ មានលាយត្រីងៀត ផ្អក និងប្រហុកចំនួន ៣ ប្រអប់ក្រដាស ពីអ្នកបើកឡានម៉ាកសាំយ៉ុង ម្នាក់មិនស្គាល់ឈ្មោះ នៅម្តុំលក់ផ្កា ផ្លូវជាសុផារ៉ា ខណ្ឌឬស្សីកែវ នៅវេលាម៉ោងប្រហែល ១២ តែដោយអ្នកមកទទួលមាន

ការឃើតយ៉ាវ ខ្លួនក៏យកគ្រឿងញៀន ៣ ដុំ នោះទៅទុកនៅកន្លែងយាមឡាននៅភូមិទូលសង្កែ ។ លុះថ្ងៃបន្ទាប់វេលាម៉ោងប្រហែល ១០ ព្រឹក ខ្លួនក៏យកគ្រឿងញៀនទៅប្រគល់ឱ្យអ្នកមកទទួលម្នាក់មិនធ្លាប់ស្គាល់នៅមុខសាលាន័រតុនសង្កាត់ជ្រោយចង្វារ ។ បន្ទាប់មកនៅវេលាម៉ោងប្រហែលជាង ១២ ឈ្មោះ [redacted] Kali បានវេរប្រាក់ឱ្យចំនួន ៣០០ ដុល្លារ ដោយផ្ញើសារលេខកូដសម្ងាត់សម្រាប់បើកលុយមកលេខទូរស័ព្ទរបស់ខ្លួន ។ លើកទី៤ នៅវេលាម៉ោងប្រហែលជាង ១០ ព្រឹក ឈ្មោះ [redacted] Kali បានទូរស័ព្ទមកខ្លួនឱ្យរង់ចាំទទួលគ្រឿងញៀនផង តែពុំបានប្រាប់ថា គ្រឿងញៀនមានចំនួនប៉ុន្មានដុំ (គីឡូក្រាម) ទេ ។ លុះវេលាម៉ោងប្រហែលជាង ១២ មានលេខ [redacted]៦៦៥ បានទូរស័ព្ទមកខ្លួនឱ្យមកទទួលឥវ៉ាន់ (គ្រឿងញៀន) នៅចំណុចអតីតរោងចក្រទឹកដោះគោ លើផ្លូវជាតិលេខ៥ សង្កាត់ទូលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ លុះពេលទៅដល់ខ្លួនបានឃើញឡានកាមរីពណ៌ខ្មៅមួយគ្រឿងឈប់នៅចំណុចណាត់ជួបខាងលើ ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងចាប់យកគ្រឿងញៀនចំនួន ០៣ ការ៉ុង (៥០ដុំ) រួចបាននាំខ្លួនមកកាន់មន្ទីរប្រឆាំងគ្រឿងញៀនដើម្បីធ្វើការសាកសួរ និងចាត់ការតាមនីតិវិធី ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយនៅតំណាក់កាលអយ្យការថា៖ ខ្លួនសូមរក្សាចម្លើយដែលបានឆ្លើយនៅចំពោះមុខសមត្ថកិច្ចទុកជាបានការដដែល ។ ខ្លួនចាប់ផ្តើមរកស៊ីជួញដូរគ្រឿងញៀនតាំងពីឆ្នាំ ២០២០ ដោយគ្រឿងញៀនរាល់ដងដែលដឹកយកទៅឱ្យម៉ូយ គឺខ្លួនទទួលការងារពីឈ្មោះ [redacted] Kali (ឈ្មោះក្នុងហ្វេសប៊ុក) ដែលមានលេខទូរស័ព្ទ [redacted] ៨៥៦៤ ដោយបានទទួលការងារពីឈ្មោះ [redacted] Kali បានប្រហែលចំនួន ៥ ទៅ ៦ ដង ដោយទទួលបានកម្រៃជើងសារក្នុង ០១ គីឡូ តម្លៃ ១០០ ដុល្លារអាមេរិក ។ នៅពេលដែលការងារបានសម្រេចទើបខ្លួនបានទទួលកម្រៃនោះ ។ ឥវ៉ាន់ដែលដឹកឱ្យភ្ញៀវ គឺវេចខ្ចប់ដាក់នៅក្នុងកេសហើយខ្លួនដឹកយកទៅឱ្យម៉ូយ តាមគោលដៅដែលឈ្មោះ [redacted] Kali ប្រាប់ ។ រាល់ឥវ៉ាន់ដែលឈ្មោះ [redacted] Kali បានទំនាក់ទំនងឱ្យខ្លួនដឹកឱ្យភ្ញៀវ ខ្លួនក៏បានដឹងថាវា គឺជាគ្រឿងញៀនដែរ ។ ចំពោះប្រាក់កម្រៃដែលខ្លួនបានមកពីការដឹកជញ្ជូនគ្រឿងញៀន ខ្លួនបានយកទៅទិញម៉ូតូម៉ាក PCX ចំនួន ០១ គ្រឿង ដូចមានក្នុងកំណត់ហេតុ និងមួយចំនួនទៀតយកទៅផ្គត់ផ្គង់ក្នុងជីវភាពគ្រួសារ ហើយចំពោះដីមួយកន្លែង និងមានសង់ផ្ទះនៅលើដីនោះ មិនមែនជាកម្មសិទ្ធិរបស់ខ្លួននោះទេ វាជាទ្រព្យរបស់ម្តាយបង្កើតរបស់ខ្លួន ។ ខ្លួនបានស្គាល់ឈ្មោះ [redacted] Kali តាមរយៈសង្សាររបស់ខ្លួនឈ្មោះ [redacted] ម៉ានីកា ភេទស្រី ដែលបច្ចុប្បន្នគាត់កំពុងជាប់នៅក្នុងមណ្ឌលអប់រំកែប្រែ ម២ ។ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ១០ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួន នៅចំណុចដីឡូតិ៍ទុកចោល សង្កាត់ទូលសង្កែ ដោយមានគ្រឿងញៀននៅនឹងខ្លួនរបស់ខ្លួនចំនួន ០១ ខាំ ។ ប្រហែលមួយសន្ទុះក្រោយមក ឈ្មោះ [redacted] ពន្លក បានទូរស័ព្ទមកខ្លួនថាមានរបស់ផ្ញើមកពីម្ចាស់លេខទូរស័ព្ទ [redacted] ៨៤៥ ៨៥៦៤ ហើយខ្លួនក៏ទៅទទួលពីឈ្មោះ [redacted] ពន្លក នៅម្តុំម៉ូឌែន៥ ដោយគ្រឿងញៀននោះទុកនៅក្នុងបាវចំនួន ០៣ បាវ ដោយមានទម្ងន់ ៥០ គីឡូក្រាម ។ ពេលនោះស្រាប់តែមានសមត្ថកិច្ចចុះមកធ្វើការបង្ក្រាបដោយបានឃាត់ខ្លួន និងដកហូតបានវត្ថុតាងដូចមានក្នុងកំណត់ហេតុចាប់យក ។ ចំពោះឈ្មោះ [redacted] ពន្លក នោះខ្លួនមិនដែលស្គាល់គាត់ពីមុននោះទេ ។ ក្រៅពីដឹកជញ្ជូនគ្រឿងញៀនយកទៅឱ្យម៉ូយដើម្បីយកប្រាក់កម្រៃ ខ្លួនក៏បានទិញគ្រឿងញៀនដើម្បីលក់ផងដែរ ។ ខ្លួនបានទិញថ្នាំញៀនដើម្បីយកមកលក់ ដោយទិញពីមនុស្សមិនស្គាល់ឈ្មោះ តែស្គាល់តាមរយៈឈ្មោះ [redacted] Kali ដោយខ្លួនធ្វើការកម្ម៉ង់ម្តងចំនួន កន្លះគីឡូ ក្នុងតម្លៃ ៣.៥០០ ដុល្លារអាមេរិក ដោយខ្លួនធ្វើការវេរលុយឱ្យគេមុន ទើបបានរបស់តាមក្រោយ ។ ខ្លួនមិនមានអាខោនគណនីនៅធនាគារណាមួយនោះទេ ហើយចំពោះផ្ទះរបស់ម្តាយបង្កើតរបស់ខ្លួនស្ថិតនៅដីឡូតិ៍លេខ៧២ សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។



Scanned with CamScanner

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយនៅតំណាក់កាលចៅក្រមស៊ើបសួរថា៖ ខ្លួនសូមទទួលស្គាល់ចម្លើយដែលខ្លួនបានឆ្លើយនៅសមត្ថកិច្ចនគរបាលទាំងអស់ ។ សមត្ថកិច្ចបានឃាត់ខ្លួននៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១០ ព្រឹក នៅចំណុចដីឡូតិ៍មិនចាំលេខ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។ នាពេលដែលខ្លួនយកគ្រឿងញៀនចំនួន ០១ខាំ ឱ្យទៅម៉ូយមិនស្គាល់ឈ្មោះប្រើប្រាស់ទូរស័ព្ទលេខ ០៨៧ [redacted]៥២៦ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួន និងដកហូតទូរស័ព្ទដៃចំនួន ០១ គ្រឿង ម៉ាក OPPO A53 លុយប្រហែល ៥ម៉ឺន ទៅ ៦ ម៉ឺន ម៉ូតូចំនួន ០១ គ្រឿង ម៉ាក PCX ពណ៌ស ស៊េរីឆ្នាំ២០១៤ ពាក់ស្លាកលេខស្វាយរៀង មិនចាំលេខ និងគ្រឿងញៀនចំនួន ០១ ខាំ ។ នៅថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ [redacted]Kali បានទូរស័ព្ទមកខ្លួនឱ្យចាំទទួលឥវ៉ាន់ផ្ញើពីខេត្ត បន្តិចទៀតគេនឹងទាក់ទងហើយ ។ ប្រហែលជា ១០ នាទីក្រោយមក មានមនុស្សប្រុសម្នាក់បានទាក់ទងមកខ្លួនដោយប្រើលេខទូរស័ព្ទក្បាល ០៧៧ និងកន្ទុយ ៦៦៥ (លេខកណ្តាលខ្លួនមិនចាំ) ដោយប្រាប់ខ្លួនថា ជួបគ្នានៅម្តុំមុខម៉ូដែន៥ ត្រីងៀតចំនួន ០៣ ការ៉ុង បានមកដល់ហើយ ខ្លួនក៏បានប្រាប់ថាចាំខ្លួនចេញទៅយក ។ ខ្លួនសូមបញ្ជាក់ថានៅពេលដែលខ្លួនឆ្លើយជាមួយអ្នកយកត្រីងៀតមកឱ្យខ្លួននោះ ខ្លួនកំពុងស្ថិតនៅក្នុងការសហការជាមួយសមត្ថកិច្ច ។ សមត្ថកិច្ចបាននាំខ្លួនទៅមុខម៉ូដែន៥ ចាំទទួលយកត្រីងៀត ហើយនៅពេលនោះក៏ឃើញអ្នកដែលយកត្រីងៀតមកតាមការណាត់ជាមួយខ្លួនខាងលើ ហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ដោយដកហូតបានត្រីងៀតចំនួន ០៣ ការ៉ុង និងរថយន្តម៉ាកបាឡែន ពណ៌ខ្មៅ ចំនួន ០១ គ្រឿង ។ ចំពោះឈ្មោះ[redacted]Kali ដែលបានប្រាប់ខ្លួនឱ្យចាំទទួលត្រីងៀតនោះខ្លួនបានដឹងច្បាស់ថា គឺជាគ្រឿងញៀន ។ ចំពោះមនុស្សប្រុសដែលប្រើលេខទូរស័ព្ទក្បាល ០៧៧ និងកន្ទុយ ៦៦៥ ជាអ្នកដឹកត្រីងៀតចំនួន ០៣ ការ៉ុង មកឱ្យខ្លួន ។ ខ្លួនមិនដែលស្គាល់គាត់ទេពីមុនមកទើបតែស្គាល់ថាជាឈ្មោះ [redacted]ពន្លក នៅពេលដែលសមត្ថកិច្ចឃាត់ខ្លួននៅមុខម៉ូដែន៥ ហើយក៏មិនដែលបានទទួលគ្រឿងញៀន ឬត្រីងៀតពីគាត់ដែរពីមុនមក ។ ខ្លួនមិនដែលស្គាល់ឈ្មោះ[redacted]ប្ញូស្តី ហៅ តៅ ទេ តាំងពីមុនមករហូតមកដល់ពេលនេះមិនដឹងថាជានរណាទេ ។ ខ្លួនបានស្គាល់ឈ្មោះ [redacted]ali តាមរយៈសង្សាររបស់ខ្លួនឈ្មោះ [redacted]ម៉ានីកា អាយុប្រហែល ២៥ឆ្នាំ ជាទណ្ឌិតនៅមណ្ឌលអប់រំកែប្រែទី២ (ម២) ដោយសារខ្លួនទៅសួរសុខទុក្ខសង្សារខ្លួនញឹកញាប់នៅ ម២ ហើយសង្សារខ្លួនបានប្រាប់ខ្លួនថា បើខ្លួនអត់ការងារអាចជួយធ្វើការងារឱ្យឈ្មោះ[redacted]Kali យកឥវ៉ាន់គ្រឿងញៀនឱ្យគេ ។ ខ្លួនមិនដែលបានជួបមុខឈ្មោះ[redacted] Kali ម្តងណាទេ គ្រាន់តែដឹងថាគាត់នៅក្នុងមណ្ឌលអប់រំកែប្រែទី២ (ម២) តាមសង្សារខ្លួនបាននិយាយប្រាប់ ។ ឈ្មោះ[redacted]Kali បានទាក់ទងមកខ្លួនតាមទូរស័ព្ទលេខ [redacted]៨៥៤៦ ។ ឈ្មោះ [redacted] Kali បានប្រើខ្លួនឱ្យយកគ្រឿងញៀនឱ្យម៉ូយចំនួនប្រហែល ៥ ទៅ ៦ ដង ។ ក្នុងម្តងៗពី ៣ ទៅ ៤ គីឡូក្រាម ដោយឈ្មោះ[redacted]Kali ឱ្យលេខទូរស័ព្ទរបស់ម៉ូយនីមួយៗមកខ្លួនឱ្យខ្លួនទាក់ទងទៅ ។ ខ្លួនមិនចាំលេខទេ (ដោយទាក់ទងហើយលុបលេខទូរស័ព្ទចោល) ។ ម៉ូយដែលមកយកគ្រឿងញៀនពីខ្លួនជួនមនុស្សប្រុស ជួនមនុស្សស្រី ខ្លួនមិនស្គាល់មុខ មិនស្គាល់ឈ្មោះ និងមិនស្គាល់អាស័យដ្ឋានទេ ដោយណាត់គ្នាតាមផ្លូវដូចម្តុំកាំកូស៊ីធី អង់តែនទួលគោក និងម្តុំជ្រោយចង្វារផ្លូវន័រគុនជាដើម ។ នៅពេលដែលខ្លួនទទួលគ្រឿងញៀនតាមការណែនាំពីឈ្មោះ [redacted]Kali ខ្លួនក៏យកគ្រឿងញៀនពីមនុស្សប្រុសដែលមិនស្គាល់ឈ្មោះនៅគ្រប់កន្លែងជួនកាលនៅផ្លូវជាសុផារ៉ា ផ្លូវជាតិលេខ៥ គល់ស្ពានជ្រោយចង្វារ តាមឡានតាក់ស៊ី ឡានព្រូស ជាដើម ។ នៅពេលខ្លួនទទួលគ្រឿងញៀនពីគេមក ខ្លួនរក្សាទុកនៅកន្លែងខ្លួនយាមឡាន យាមម៉ូតូនៅចំណុចដីឡូតិ៍មិនចាំលេខខាងលើ ដែលគេទុកចោលស្ថិតនៅទួលសង្កែ ។ ប្រហែលជា ២ ម៉ោង ទៅ ៣ ម៉ោង ក្រោយមកទើបដឹកជញ្ជូនយកទៅឱ្យម៉ូយតាមម៉ូតូរបស់ខ្លួនខាងលើ ។ ខ្លួនមិនបានទូទាត់លុយគ្រឿងញៀនជាមួយម៉ូយ ឬកាន់លុយពីម៉ូយទៅឱ្យឈ្មោះ [redacted]ali ទេ គឺមិនដឹងថ[redacted]Kali និងម៉ូយទូទាត់លុយគ្នាយ៉ាងម៉េចទេ ។ ខ្លួនមានទំនាក់ទំនងជាមួយ

65/13



Scanned with CamScanner

ឈ្មោ[redacted]Kali តាំងពីខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃសមត្ថកិច្ចឃាត់ខ្លួន និងរកស៊ីគ្រឿងញៀនតាំងពីពេលនោះមក ដោយធ្វើសកម្មភាពតែម្នាក់ឯង តាមការណែនាំ និងបង្គាប់បញ្ជាពីឈ្មោះ [redacted] Kali ។ ចំពោះសង្សារខ្លួនបានដឹងថាខ្លួនធ្វើការឱ្យឈ្មោះ [redacted]Kali ដែរ តែគាត់មិនបានចូលរួមធ្វើការងារពាក់ព័ន្ធនឹងគ្រឿងញៀនជាមួយខ្លួន និងឈ្មោះ [redacted]Kali ទេ ។ ខ្លួនបានទទួលលុយថ្លៃជួយលក់គ្រឿងញៀន រក្សាទុក និងដឹកជញ្ជូន ឱ្យឈ្មោះ [redacted] Kali ក្នុងមួយគីឡូគ្រឿងញៀនបាន ១០០ដុល្លារអាមេរិក ។ ចំពោះប្រាក់បានមកពីគ្រឿងញៀនខ្លួនយកទៅទិញម៉ូតូម៉ាក PCX ពណ៌ស ស៊េរីឆ្នាំ២០១៤ ពាក់ស្លាកលេខស្វាយរៀង (មិនចាំលេខ) ទិញនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ ផ្គត់ផ្គង់គ្រួសារ ប្រពន្ធកូនឱ្យទៅសង្សារឈ្មោះ [redacted]ម៉ានីកា ហើយខ្លួនមិនមានផ្ទះ ឡានផ្ទាល់ខ្លួនទេ ហើយខ្លួនក៏មិនមានលុយនៅក្នុងធនាគារទេ ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted]ពិសិដ្ឋ បានឆ្លើយនៅតំណាក់កាលចៅក្រមស៊ើបសួរលើកទី២ថា៖ នៅសមត្ថកិច្ចនគរបាលខ្លួនពុំបានឆ្លើយថា "ចំណែកឯលុយដែលបានមកពីកម្រៃដឹកជញ្ជូន និងជួញដូរគ្រឿងញៀនខ្ញុំបានយកទៅទិញដីមួយកន្លែង និងសង់ផ្ទះនៅក្នុងសង្កាត់ក្រាំងធ្នង់ និងទិញម៉ូតូចំនួន ០១ គ្រឿង" នោះទេ ខ្លួនសូមបដិសេធចម្លើយនេះ ។ ខ្លួនគ្រាន់តែបានឆ្លើយថាកម្រៃដែលបានមកពីដឹកជញ្ជូន និងជួញដូរគ្រឿងញៀន បានទិញម៉ូតូចំនួន ០១ គ្រឿង និងផ្គត់ផ្គង់កូនៗប្រពន្ធដើមចំនួន ០៣ នាក់ នៅខេត្តសៀមរាប និងមួយចំនួនទៀតទុកសម្រាប់ចាយវាយ ។ ចំពោះដីផ្ទះនៅសង្កាត់ក្រាំងធ្នង់ ពិតជាមានមែន ប៉ុន្តែម្តាយខ្លួនឈ្មោះ[redacted]ប៉ុល បានឱ្យខ្លួនតាំងពីប្រាំមួយឆ្នាំមុនប្រហែលចុងឆ្នាំ២០១៥ ។ ដីនេះនៅមានឈ្មោះម្តាយខ្លួនជាអ្នកគ្រប់គ្រងនៅឡើយ ម្តាយខ្លួនថាឱ្យខ្លួន ប៉ុន្តែគាត់មិនទាន់កាត់ឈ្មោះមកឱ្យខ្លួននៅឡើយទេ ។ ចំណែកសំណង់ផ្ទះនៅលើដីនេះខ្លួនមិនបានចំណាយលុយសាងសង់ទេ គឺជាលុយម្តាយរបស់ខ្លួនសុទ្ធសាធ ។ និយាយរួមផ្ទះ និងដីនេះជារបស់ម្តាយខ្លួន គាត់គ្រាន់តែឱ្យខ្លួនស្នាក់នៅព្រោះគាត់មិនទាន់បានផ្ទេរឈ្មោះមកឱ្យខ្លួនទេ ។

-ជនជាប់ចោទឈ្មោ[redacted]ពិសិដ្ឋ បានឆ្លើយថា ៖ ខ្លួនជួយលក់ថ្នាំញៀនឱ្យឈ្មោះ[redacted]Kali ដែលខ្លួនស្គាល់នាពេលខ្លួនទៅសួរសុខទុក្ខមិត្តភក្តិនៅ ម២ ហើយមិត្តភក្តិប្រាប់ថា បើអត់មានការងារទេ ជួយធ្វើការឱ្យឈ្មោះ [redacted] Kali ទៅស្របពេលដែលខ្លួនអត់មានការងារផងនោះខ្លួនក៏ជួយធ្វើការឱ្យឈ្មោះ[redacted] Kali ទៅ ។ ខ្លួនចាប់ផ្តើមជួយការងារឈ្មោះ [redacted] Kali លក់គ្រឿងញៀននៅពាក់កណ្តាលឆ្នាំ២០២០ ហើយប្រាក់ដែលបានពីការលក់ថ្នាំញៀននេះ ខ្លួនបានទិញម៉ូតូ ០១គ្រឿង និងចិញ្ចឹមប្រពន្ធកូន ។ សមត្ថកិច្ចឃាត់ខ្លួននៅគោលដៅទី១ រកឃើញថ្នាំញៀនទម្ងន់ ១០០ក្រាម ហើយខ្លួនបានសហការនៅជាមួយសមត្ថកិច្ចនៅពេលមានគេទាក់ទងឱ្យទៅយកថ្នាំញៀន រហូតឃាត់ខ្លួនឈ្មោះ [redacted] ពន្លក ដែលដឹកគ្រឿងញៀនមកដល់គោលដៅទី២ ។ ខ្លួនមិនដឹងថាមានថ្នាំញៀនប៉ុន្មាននោះទេ ។ បន្ទាប់មកសមត្ថកិច្ចបានឱ្យខ្លួននាំទៅគោលដៅទី៣ រកឃើញថ្នាំញៀន ៣០០ ក្រាម ។ ចំពោះផ្ទះដែលតុលាការបានបង្កក វាជាផ្ទះម្តាយរបស់ខ្លួនតាំងពីឆ្នាំ២០១៤ គាត់ថាចែកផ្ទះនេះឱ្យខ្លួន ប៉ុន្តែមិនទាន់បានចែកនោះទេ ។ សព្វថ្ងៃប្រពន្ធកូនខ្លួនរស់នៅផ្ទះនោះជាមួយម្តាយប៉ុណ្ណោះ ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ពន្លក បានឆ្លើយនៅតំណាក់កាលសមត្ថកិច្ចថា៖ វត្ថុតាងជាម្សៅក្រាមពណ៌សថ្លាចំនួន ០៣ ការ៉ុង (ហាសិបដុំ) ដែលសមត្ថកិច្ចបានដកហូតចេញពីគូទឡាន ខ្លួនទើបតែដឹងថាជាគ្រឿងញៀន ព្រោះឈ្មោះ ពៅ ប្រាប់ខ្លួនថាជាត្រីងៀតឱ្យដឹកពីខេត្តក្រចេះមកភ្នំពេញ ។ ខ្លួនស្គាល់ឈ្មោះ ពៅ ពីព្រោះគាត់ត្រូវជាមិត្តភក្តិរបស់បងប្រុសជីដូនមួយរបស់ខ្លួនដែលរស់នៅផ្សារកន្ទួត ។ ខ្លួនឮថាឈ្មោះ ពៅ ជាប់ពន្ធនាគារមួយរយៈមិនដឹងជាប់ពីបទអ្វីទេ ។ លុះដល់ថ្ងៃមិនចាំ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១០ ព្រឹក ឈ្មោះ ពៅ នៅជាប់ពន្ធនាគារព្រៃស (ម១) បានទូរស័ព្ទមកសួរសុខទុក្ខខ្លួនថា៖ "ពន្លកមែន? សុខសប្បាយអត់? ស្គាល់បងអត់?" រួច



Scanned with CamScanner

65/11

គាត់សួរខ្លួនថា៖ "រាល់ថ្ងៃធ្វើការងារអ្វី?" ខ្លួនប្រាប់វិញថា អត់ធ្វើការងារអីទេសម័យកូវីដ រួចក៏ចុចបិទ ។ ស្អែកគាត់បានទូរស័ព្ទមកខ្លួនម្តងទៀត សួររកប្រព័ន្ធលេខស្អាត ដើម្បីទំនាក់ទំនងតាមតេឡេក្រាម ។ នៅពេលដែលខ្លួនទទួលការងារដឹកជញ្ជូនគ្រឿងញៀនរួច ខ្លួនក៏ទំនាក់ទំនងតាមតេឡេក្រាមទៅឈ្មោះ តៅ ទៅវិញទៅមក ខ្លួនតែងតែលុបឆាតចោល ។ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែល ១០ ព្រឹក ឈ្មោះ តៅ បានទូរស័ព្ទមកខ្លួនឱ្យយកឡានគាត់ ហើយវេរលុយចំនួន ១០០ ដុល្លារ ដើម្បីឱ្យខ្លួនចាក់សាំងឡាន និងសាហ៊ុយធ្វើដំណើរ រួចឱ្យខ្លួនបើកឡានទៅខេត្តក្រចេះ ។ ពេលទៅដល់ខេត្តក្រចេះ ម៉ោងប្រហែល ១៨ ល្ងាច ខ្លួនក៏ទូរស័ព្ទប្រាប់គាត់ រួចគាត់ប្រាប់ឱ្យខ្លួនដេកនៅខេត្តស្ទឹងត្រែង ពីព្រោះគេ (ម្ចាស់គ្រឿងញៀន) ជាអ្នកខេត្តស្ទឹងត្រែង ។ នៅម៉ោងប្រហែល ៤ ព្រឹក ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ តៅ បានទំនាក់ទំនងតាមតេឡេក្រាមមកខ្លួនដោយឱ្យលេខទូរស័ព្ទ [redacted] ០១២៦ (លេខម្ចាស់គ្រឿងញៀន) រួចខ្លួនបានទូរស័ព្ទទៅទំនាក់ទំនងតាមលេខទូរស័ព្ទខាងលើ ប្រាប់គាត់ថាឥឡូវខ្លួនមកទទួលឥវ៉ាន់ (គ្រឿងញៀន) រួចគាត់ប្រាប់ឱ្យខ្លួនទៅចាំនៅស្ថានីយ៍ចាក់សាំង PTT (អូរគ្រៀង) ។ លុះទៅដល់វេលាម៉ោងប្រហែល ៦ ជាង ខ្លួនទូរស័ព្ទទៅលេខខាងលើប្រាប់ថា ខ្លួនមកដល់ហើយ កំពុងតែចាក់សាំង គាត់ក៏ប្រាប់វិញថា ជិតទៅដល់ហើយ ពេលនោះក៏ឃើញរថយន្តម៉ាក Mazda ពណ៌ស ស្លាកលេខ ស្ទឹងត្រែង (មិនចាំលេខ) ចូលចាក់សាំងដែរ តែខ្លួនស្មានថា រថយន្តម្ចាស់គ្រឿងញៀន ហើយខ្លួនបើកចេញរួចបានទូរស័ព្ទទៅលេខខាងលើ គាត់ក៏ឱ្យខ្លួនបើកឡានចេញមកលើផ្លូវជាតិ គាត់មកជិតដល់ហើយ ។ ពេលឈប់ ចាំបានប្រហែល ៥ នាទី ក៏ឃើញឡានម៉ាក Mazda ពណ៌សពាក់ស្លាកលេខស្ទឹងត្រែងដូចឡានចាក់សាំងខាងលើ ។ ពេលឃើញខ្លួនក៏ចុចកញ្ចក់ឡានចុះដូចគ្នាទៅវិញទៅមក និងលើកដៃជាសញ្ញា ហើយក៏ចុះពីលើឡានបើកគូទឡានក្រោយដូចគ្នា ។ គាត់ក៏លើកឥវ៉ាន់ចំនួន ០៣ ការ៉ុង (គ្រឿងញៀន) ចូលគូទឡានរបស់ខ្លួន រួចក៏បើកឡានចេញបញ្ច្រាស់ទិសគ្នាទៅ ។ ពេលកំពុងធ្វើដំណើរខ្លួនបានទំនាក់ទំនងតាមតេឡេក្រាមទៅឈ្មោះ តៅ ថាខ្លួនបានទទួលឥវ៉ាន់ហើយ ។ ពេលមកដល់ស្រុកបាធាយខ្លួនទំនាក់ទំនងតាមតេឡេក្រាមទៅប្រាប់ឈ្មោះ តៅ ហើយគាត់ប្រាប់ថា អញ្ជើងប្អូនឯងបើកមកតិចៗចាំបងទម្លាក់លេខទូរស័ព្ទ ០៩៥ ៩១០ ០០៥ អ្នកទទួលឥវ៉ាន់គ្រឿងញៀន ។ ពេលមកដល់ស្ពានព្រែកតាមាក់ខ្លួនទូរស័ព្ទទៅលេខអ្នកចាំទទួលឥវ៉ាន់ ហើយណាត់ជួបគ្នានៅមុខប៊ូរីម៉ែន៥ ភូមិសាមគ្គី ខណ្ឌឫស្សីកែវ នៅពេលដែលមកដល់កន្លែងណាត់ជួបក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ទើបដឹងថានៅក្នុងការ៉ុងគ្រឿងញៀនសុទ្ធថ្នាំញៀនទៅវិញ ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ពន្លក បានឆ្លើយនៅតំណាក់កាលអយ្យការថា៖ ខ្លួនសូមរក្សាចម្លើយដែលបានឆ្លើយ នៅចំពោះមុខសមត្ថកិច្ច ទុកជាបានការដដែល ។ កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ តៅ ភេទប្រុស អាយុ៣៨ឆ្នាំ សម្បុរស កម្ពស់ប្រហែល ១,៦០ ម៉ែត្រ (បច្ចុប្បន្នជាប់ឃុំនៅមណ្ឌលកែប្រែ ម១) បានទូរស័ព្ទមកខ្លួនថាឱ្យជួយយកឥវ៉ាន់គ្រឿងញៀនចំនួន ០៣ បាវ ដោយបានឱ្យលេខទូរស័ព្ទ ០៩៥ ៩១០ ០០៥ ដែលជាអ្នកទទួលឥវ៉ាន់ ដោយគាត់រស់នៅទីក្រុងភ្នំពេញ គាត់ឱ្យកម្រៃជើងសារថ្លៃដឹកចំនួន ៣ ពាន់ ដុល្លារអាមេរិក តែខ្លួនមិនទាន់បានលុយចំនួន ៣ ពាន់ ដុល្លារអាមេរិកនោះទេ ។ បានតែចំនួន ៥០០ ដុល្លារអាមេរិក ពីឈ្មោះ តៅ ដោយគាត់វេរលុយឱ្យខ្លួនតាមវីង ។ គ្រឿងញៀនចំនួន ០៣ បាវ ដែលឈ្មោះ តៅ បានឱ្យខ្លួនដឹកនៅខេត្តក្រចេះ ។ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ ខ្លួនបានទទួលគ្រឿងញៀននោះហើយក៏បានរៀបចំដាក់ឡានយកឱ្យម៉ូយនៅភ្នំពេញ ។ នៅថ្ងៃដដែល ខ្លួនក៏បានដឹកឥវ៉ាន់ឱ្យម៉ូយ (ដោយដឹកដោយឡាន TOYOTA CAMRY ពណ៌ខ្មៅ ស្លាកលេខ 2T-6441) តាមរយៈលេខទូរស័ព្ទដែលឈ្មោះ តៅ បានឱ្យនោះ ។ នៅពេលដឹកពីខេត្តក្រចេះមកដល់ភ្នំពេញ ខ្លួនបានយកគ្រឿងញៀននោះទៅឱ្យម៉ូយនៅម្តុំប៊ូរីម៉ែន៥ លុះពេលទៅដល់គាត់បានទំនាក់ទំនងទៅឈ្មោះ[redacted]ពិសិដ្ឋ ហើយឈ្មោះ [redacted] ពិសិដ្ឋ បានមកយកគ្រឿងញៀននៅចំណុច

ណាត់ជួបខាងលើ ។ បន្ទាប់ស្រាប់តែមានសមត្ថកិច្ចចុះបង្ក្រាប និងធ្វើការត្រួតពិនិត្យ បានរែករេរឃើញថ្នាំញៀននៅក្នុងបាវដាក់ត្រីងៀតនោះ ទើបខ្លួនដឹងថាក្នុងបាវត្រីងៀតនោះមានគ្រឿងញៀន ។ ចំពោះការដឹកឥវ៉ាន់ឱ្យឈ្មោះ ពៅ ខ្លួនទើបតែដឹកឱ្យគាត់លើកទី១ តែប៉ុណ្ណោះ ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ពន្លក បានឆ្លើយនៅតំណាក់កាលចៅក្រមស៊ើបសួរថា៖ វេលាម៉ោងប្រហែល១ ថ្ងៃត្រង់ នៅមុខម៉ូតែន៥ ពេលខ្លួនកំពុងអង្គុយក្នុងឡានរងចាំអ្នកមកទទួលត្រីងៀត ។ សមត្ថកិច្ចបានដកហូតត្រីងៀតចំនួន ០៣ ការ៉ុង ទូរស័ព្ទដៃចំនួន ២ គ្រឿង ម៉ាក Samsung ០១ គ្រឿង មានស៊ីមលេខ [redacted] ៦៦៥ និងម៉ាក OPPO ០១ គ្រឿង មានស៊ីមលេខ [redacted] ១៧២ និងលេខមួយខ្សែទៀតខ្លួនមិនចាំ កាបូបលុយ (គ្មានលុយ) ឡានចំនួន ០១ គ្រឿង ម៉ាក CAMRY ជាឡែន ពណ៌ខ្មៅ ។ ក្រោយមកទើបខ្លួនដឹងថាក្នុងការ៉ុងត្រីងៀតនោះមានគ្រឿងញៀនដោយសារប៉ូលីសចាក់ការ៉ុងត្រីងៀតចេញមកឃើញគ្រឿងញៀនក្នុងការ៉ុងទាំង ៣ ។ នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ ពៅ បានទូរស័ព្ទប្រាប់ខ្លួនតាមរយៈតេឡេក្រាមដែលមានលេខ [redacted] ៨៨៤ ថាឱ្យខ្លួនទៅដឹកត្រីងៀតនៅខេត្តក្រចេះចំនួន ០៣ ការ៉ុង យកមកភ្នំពេញ ។ គាត់ថាទៅដល់ក្រចេះទាក់ទងលេខ [redacted] ០១២៦ ដែលជាម្ចាស់ត្រីងៀត ។ នៅពេលមកដល់ភ្នំពេញទាក់ទងលេខ [redacted] ០០៥ ជាអ្នកទទួលត្រីងៀត ។ ខ្លួនបានចេញដំណើរពីភ្នំពេញនៅម៉ោង ២ រសៀល ទៅដល់ក្រចេះនៅម៉ោង ៦ ល្ងាច ខ្លួនបានទាក់ទងទៅឈ្មោះ ពៅ ហើយឈ្មោះ ពៅ បានប្រាប់ខ្លួនថាឱ្យខ្លួនបើកឡានទៅដេកនៅស្ទឹងត្រែងតែម្ដងទៅ ព្រោះយប់ហើយ ។ លុះព្រឹកឡើងថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ ខ្លួនចេញពីខេត្តស្ទឹងត្រែងមកខេត្តក្រចេះ ហើយទាក់ទងទៅលេខទូរស័ព្ទ [redacted] ០១២៦ ដែលជាម្ចាស់ត្រីងៀត ហើយម្ចាស់ត្រីងៀតក៏ឱ្យខ្លួនបើកឡានមកការ៉ាស់សាំង PTT ហើយខ្លួនក៏ទាក់ទងទៅម្ដងទៀតម្ចាស់ត្រីងៀត ថាឱ្យបើកឡានចេញពីការ៉ាស់សាំងមកផ្លូវជាតិពេលនោះក៏បានជួបគ្នា ។ ម្ចាស់ត្រីងៀតបានឱ្យខ្លួនបើកគូទឡានហើយម្ចាស់ត្រីងៀតក៏លើកត្រីងៀតទាំង ០៣ ការ៉ុង នោះដាក់គូទឡានខ្លួនរួចខ្លួនក៏បើកឡានចេញមកភ្នំពេញតែម្ដង ។ ពេលមកដល់ភ្នំពេញខ្លួនទាក់ទងទៅឈ្មោះ ពៅ ដោយប្រាប់ថាខ្លួនមកដល់ភ្នំពេញហើយ ឈ្មោះ ពៅ បានប្រាប់ខ្លួនឱ្យទាក់ទងទៅលេខ ០៩៥ ៩១០ ០០៥ ដែលជាអ្នកមកទទួលត្រីងៀត ហើយខ្លួនក៏ទាក់ទងទៅ រួចអ្នកដែលមកយកត្រីងៀតនោះប្រាប់ខ្លួនថាឱ្យយកទៅម៉ូតែន៥ តែម្ដងទៅ ។ ខ្លួនក៏ធ្វើតាមនៅពេលនោះសមត្ថកិច្ចក៏ឃាត់ខ្លួនតែម្ដង ។ ក្នុងដំណើររបស់ខ្លួនពីភ្នំពេញទៅយកត្រីងៀតនៅខេត្តក្រចេះមានទំនាក់ទំនងជាមួយតែឈ្មោះ ពៅ ដែលប្រើប្រព័ន្ធតេឡេក្រាមមានលេខ ០១៥ ៥៥៣ ៨៨៤ ម្ចាស់ត្រីងៀត ដែលប្រើទូរស័ព្ទលេខ [redacted] ០១២៦ និងអ្នកទទួលត្រីងៀតដែលប្រើទូរស័ព្ទលេខ ០៩៥ ៩១០ ០០៥ តែប៉ុណ្ណោះ ពុំមានទំនាក់ទំនងជាមួយអ្នកណាទៀតទេ ។ ខ្លួនស្គាល់ឈ្មោះ ពៅ ដោយសារគាត់ជាមិត្តភក្តិរបស់បងជីដូនមួយខ្លួនឈ្មោះ ឬ ដែលគាត់បានស្លាប់បាត់ហើយ ។ ខ្លួនស្គាល់ឈ្មោះ ពៅ យូរហើយ ប៉ុន្តែមិនដែលទំនាក់ទំនងជាមួយគ្នាទេ ទើបតែទំនាក់ទំនងគ្នាពេលដឹកត្រីងៀតហ្នឹង ដោយសារឈ្មោះ ពៅ បានទាក់ទងមកលេខខ្លួន [redacted] ៦៦៥ ហើយខ្លួនក៏មិនដឹងថាគាត់ បានលេខខ្លួនពីណាដែរ រួចឈ្មោះ ពៅ បានប្រាប់ខ្លួនថាគាត់កំពុងតែជាប់នៅក្នុងពន្ធនាគារ ម១ ។ នៅពេលដែលឈ្មោះ ពៅ បានឱ្យខ្លួនទៅដឹកត្រីងៀតគាត់បានសន្យាឱ្យលុយខ្លួនចំនួន ៣,០០០ ដុល្លារអាមេរិក តែខ្លួនបានទទួលលុយពីឈ្មោះ ពៅ បានចំនួន ៥០០ ដុល្លារអាមេរិករួចមកហើយ គឺថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១ ដោយឈ្មោះ ពៅ វេរតាមវីងមកឱ្យ ។ ខ្លួនមិនស្គាល់សាវតាររបស់ឈ្មោះ ពៅ ទេ តែគាត់មានអាយុប្រហែល ៣៨ឆ្នាំ ហើយក៏មិនដឹងអាសយដ្ឋានគាត់នៅទីណាដែរ ដឹងថាគាត់កំពុងតែជាប់នៅក្នុងពន្ធនាគារព្រៃស (ម១) ហើយម្ចាស់តីងៀតនោះ ខ្លួនមិនដែលស្គាល់ទេពីមុនមក ទើបតែស្គាល់ក្រោយឃាត់ខ្លួនជាមួយខ្លួនបាន ០៣ ថ្ងៃ គឺឈ្មោះ [redacted] ពិសិដ្ឋ មានអាយុប្រហែល៣៧ឆ្នាំ ហើយក៏មិនដឹងអាសយដ្ឋានរបស់គាត់ដែរ ។ ខ្លួនមិនដែលរកស៊ីលក់ដូរគ្រឿងញៀនទេ ទើបតែដឹកត្រីងៀតឱ្យឈ្មោះ ពៅ ហើយក៏មិនដឹងថានៅក្នុងការ៉ុងត្រីងៀតនេះជាគ្រឿងញៀនដែរ លុះដល់សមត្ថកិច្ចចាក់ការ៉ុងចេញមកទើបឃើញថាមានគ្រឿងញៀន ។ រថយន្តចំនួន ០១ គ្រឿង ដែលសមត្ថកិច្ចដកហូតនោះ ខ្លួនបានជួលពីឈ្មោះ [redacted] មាន អាសយដ្ឋាននៅផ្សារកន្ទួត ខេត្តកណ្ដាល ខ្លួនជួលក្នុងរយៈពេល ០១ ថ្ងៃ តម្លៃ ១០០ ដុល្លារអាមេរិក ។ ខ្លួនរស់នៅផ្ទះស្ថិតនៅភូមិស្រែគោក ឃុំអន្លង់រមៀត ស្រុកកណ្ដាលស្ទឹង

65/9

ខេត្តកណ្ដាល ផ្ទះនេះជាកម្មសិទ្ធិរបស់យាយខ្លួនឈ្មោះ [redacted] សាយ អាយុ៨៥ឆ្នាំ ។ ខ្លួនពុំមានម៉ូតូ ឡាន ឬទ្រព្យសម្បត្តិអ្វីផ្សេងទៀតទេ ។

-ជនជាប់ចោទឈ្មោះ [redacted] ពន្លក បានឆ្លើយថា ៖ ឈ្មោះ [redacted] សួស្ដី បានឱ្យខ្លួនដឹកត្រីងៀតឱ្យគេ ដឹកពីខេត្តក្រចេះមកភ្នំពេញ ដោយសន្យាឱ្យថ្លៃដឹកចំនួន ៣.០០០ $ ។ ខ្លួនបានសួរទាំថា ដឹកអ្វី? ប៉ុន្តែឈ្មោះ [redacted] សួស្ដី ប្រាប់វិញថា គ្រាន់តែធ្វើតាមទៅបានហើយ ។ ខ្លួនទទួលបានប្រាក់ចំនួន ៥០០$ ហើយជួលឡានគេទៅខេត្តក្រចេះយកត្រីងៀត ៣ ការ៉ុង ពីបុរសម្នាក់មិនស្គាល់ រួចហួសទៅសម្រាកនៅខេត្តស្ទឹងត្រែង ០១យប់ ទើបត្រឡប់មកភ្នំពេញដើម្បីយកទៅឱ្យគេតាមលេខទូរស័ព្ទ ។ មិនទាន់បានប្រគល់ផងក៏ត្រូវសមត្ថកិច្ចឆែកឆេរ ទើបដឹងថានៅក្នុងការ៉ុងនោះជាថ្នាំញៀន ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សួស្ដី ហៅ ពៅ បានឆ្លើយនៅតំណាក់កាលសមត្ថកិច្ចថា ៖ ខ្លួនបានស្គាល់ឈ្មោះ [redacted] ពន្លក ពិតមែន វាត្រូវជាប្អូនរបស់មិត្តភក្តិរបស់ខ្លួន ។ លេខទូរស័ព្ទដែលខ្លួនប្រើដើម្បីទំនាក់ទំនងគឺលេខ [redacted]៥៩ ឯឈ្មោះ ពន្លក ប្រើលេខ ០៨៧ ៩៨៣ ១៧២ ។ ខ្លួនស៊ីឈ្នួលដឹកជញ្ជូនឱ្យគេ ១ ជើងគេឱ្យ ៧.០០០ ដុល្លារ ដោយខ្លួនទទួលយកមកពីខេត្តស្ទឹងត្រែងហើយអ្នកបញ្ជាឱ្យខ្លួនដឹកជញ្ជូននោះខ្លួនមិនស្គាល់ឈ្មោះទេ តែគាត់និយាយភាសាខ្មែរច្បាស់ធម្មតា ជាមនុស្សប្រុស ហើយជិះឡានម៉ាក Mazda និងប្រើទូរស័ព្ទលេខ ០៧១ ៩០០ ០១២៦ ។ ខ្លួនពិតជាបានបញ្ជាឱ្យឈ្មោះ [redacted] ពន្លក ទៅដឹកជញ្ជូនគ្រឿងញៀនពីខេត្តក្រចេះ មកភ្នំពេញពិតប្រាកដមែន ប៉ុន្តែខ្លួនបានប្រាប់ឈ្មោះ [redacted] ពន្លក ថាឱ្យគាត់ដឹកជញ្ជូនត្រីងៀតចំនួន ០៣ ការ៉ុង ពីខេត្តក្រចេះមកភ្នំពេញ និងមិនបានប្រាប់គាត់ថាជាគ្រឿងញៀននោះទេ ។

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] សួស្ដី ហៅ ពៅ បានឆ្លើយនៅតំណាក់កាលចៅក្រមស៊ើបសួរថា ៖ ខ្លួនជាប់ពន្ធនាគារតាំងពីឆ្នាំ២០១៧ ខ្លួនត្រូវតុលាការរាជធានីភ្នំពេញផ្តន្ទាទោសដាក់ពន្ធនាគារកំណត់មួយជីវិតពីបទប្លន់សម្លាប់ ។ ខ្លួនសូមទទួលស្គាល់ចម្លើយដែលបានឆ្លើយនៅសមត្ថកិច្ចនគរបាល កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១ ។ កាលពីថ្ងៃមិនចាំ ក្នុងខែកក្កដា ឆ្នាំ២០២១ ខ្លួនបានពឹងពាក់អ្នកលក់ដូរក្នុងពន្ធនាគារព្រៃស (ម១) ឱ្យជួយហៅឈ្មោះ [redacted] ពន្លក ឱ្យមកជួបខ្លួន នៅពន្ធនាគារព្រៃស (ម១) ដោយខ្លួនឱ្យលេខទូរស័ព្ទរបស់ឈ្មោះ [redacted] ពន្លក ទៅអ្នកលក់ដូរ ហើយឈ្មោះ សុខ ពន្លក បានមកជួបខ្លួន ។ ពេលនោះខ្លួនបានប្រាប់ឈ្មោះ [redacted] ពន្លក ថាបានឱ្យលេខទូរស័ព្ទ ពន្លក ឯងទៅគេ បើគេតេហៅទៅយកត្រីងៀតចំនួន ០៣ ការ៉ុង នៅខេត្តក្រចេះទៅយកមក ។ មុនពេលឈ្មោះ [redacted] ពន្លក មកជួបខ្លួនរយៈពេល ៧ ថ្ងៃ មានមនុស្សប្រុសម្នាក់ឈ្មោះ រ៉ា នៅខេត្តក្រចេះបានតេទូរស័ព្ទមករកខ្លួន តែខ្លួនមិនចាំលេខ ដោយនិយាយប្រាប់ខ្លួនថាឱ្យឡើងទៅយកត្រីងៀតចំនួន ០៣ ការ៉ុង ទើបខ្លួនឱ្យឈ្មោះ [redacted] ពន្លក ត្រៀមចាំឡើងទៅយកត្រីងៀត ។ ក្នុងការដឹកត្រីងៀតចំនួន ០៣ ការ៉ុង ឈ្មោះ រ៉ា បានសន្យាថាឱ្យលុយខ្លួនចំនួន ៧.០០០ ដុល្លារអាមេរិក ក្នុងការដឹកត្រីងៀតពីខេត្តក្រចេះមកភ្នំពេញ ០១ ជើង ។ ខ្លួនមិនទាន់បានទទួលលុយចំនួន ៧.០០០ ដុល្លារអាមេរិក ទេ ។ ខ្លួនឱ្យឈ្មោះ ពន្លក ចំនួន ៥០០ ដុល្លារអាមេរិក ។ ខ្លួនបានទទួលការដឹកត្រីងៀតចំនួន ០៣ ការ៉ុង ពីឈ្មោះ រ៉ា ទើបតែម្ដងនេះទេ ។ ឈ្មោះ [redacted] ពន្លក ក៏ទើបតែដឹកត្រីងៀតឱ្យឈ្មោះ រ៉ា តែម្ដងនេះដែរ ហើយឈ្មោះ ពន្លក នេះមិនបានដឹងថាជាគ្រឿងញៀនទេ ។ ខ្លួនមិនដែលទទួលដឹកគ្រឿងញៀនពីអ្នកណាផ្សេងទៀតទេ ហើយខ្លួនក៏មិនដឹងសាវតា និងអាសយដ្ឋានរបស់ឈ្មោះ រ៉ា ទេ ។ ឈ្មោះ រ៉ា បានតេមក លេខទូរស័ព្ទរបស់ខ្លួន និងប្រាប់ឱ្យខ្លួនរកមនុស្សទៅយកត្រីងៀតខាងលើ ។ ខ្លួនមិនបានឱ្យលេខទូរស័ព្ទរបស់ឈ្មោះ [redacted] ពិសិដ្ឋ ឱ្យទៅឈ្មោះ [redacted] ពន្លក ទេ ហើយខ្លួនមិនដែលស្គាល់ឈ្មោះ [redacted] ពិសិដ្ឋ ទេតាំងពីមុនរហូតដល់ពេលនេះ ។ ខ្លួនគ្រាន់តែទទួលដឹកត្រីងៀតចំនួន ០៣ ការ៉ុង ពីខេត្តក្រចេះមកភ្នំពេញឱ្យឈ្មោះ រ៉ា តែប៉ុណ្ណោះ ។ ខ្លួនមិនដឹងថានៅក្នុងការ៉ុងនោះមានគ្រឿងញៀនទេ ។ មុនពេលខ្លួនជាប់ពន្ធនាគារខ្លួនពុំមានផ្ទះសម្បែង និងទ្រព្យសម្បត្តិអ្វីទេ ខ្លួនរស់នៅផ្ទះជួល នៅខណ្ឌច្បារអំពៅ ។



Scanned with CamScanner

-ជនជាប់ចោទឈ្មោះ [redacted] សួស្តី ហៅ តៅ បានឆ្លើយថា៖ ខ្លួនពិតជាបានជួលឈ្មោះ [redacted] ពន្លក ឱ្យដឹកត្រីងៀត ពោការ៉ុង ពីខេត្តក្រចេះ មកភ្នំពេញ តាមលេខទូរស័ព្ទដែលឈ្មោះ [redacted] ពន្លក ជាអ្នកឱ្យហើយយកមកប្រគល់ឱ្យអ្នកទិញ តាមលេខទូរស័ព្ទដែរ ។ ឈ្មោះ [redacted] ពន្លក មិនបានដឹកថាក្នុងការ៉ុងនោះជាថ្នាំញៀនទេ ។ ខ្លួនសន្យាឱ្យថ្លៃដឹកចំនួន ៣.០០០$ តែដំបូងខ្លួនឱ្យទៅឈ្មោះ [redacted] ពន្លក ៥០០$ សិន ។

-ឈ្មោះ [redacted] ប៊ុល (ត្រូវជាម្តាយរបស់ឈ្មោះ [redacted] ពិសិដ្ឋ) បានបំភ្លឺថា៖ ផ្ទះដែលតុលាការបិទនេះជាផ្ទះរបស់ខ្លួន ។ ផ្ទះនេះជាលុយរបស់ខ្លួនផ្ទាល់ មិនមែនបានពីកូនខ្លួនឈ្មោះ [redacted] ពិសិដ្ឋ លក់គ្រឿងញៀនទេ ។ ខ្លួនលក់ដីនៅទួលសង្កែបានប្រាក់ចំនួន ៥៨.០០០$ បន្ទាប់មកក៏ទិញដីឡូត៍នៅក្រាំងធ្នង់ ២ឡូត៍ តម្លៃ ១៩.៨០០$ ហើយខ្លួនក៏ឱ្យកូនឈ្មោះ [redacted] ពិសិដ្ឋ រកជាងមកធ្វើផ្ទះ សល់ ២.០០០$ ទៀត ។ ខ្លួនរស់នៅផ្ទះនេះ និងបានឱ្យកូនឈ្មោះ [redacted] ពិសិដ្ឋ និងប្រពន្ធកូនវាមករស់នៅជាមួយដែរ ។ ខ្លួនធ្លាប់បាននិយាយថានឹងចែកផ្ទះនេះឱ្យទៅកូនឈ្មោះ [redacted] ពិសិដ្ឋ ប៉ុន្តែមិនទាន់បានចែកឱ្យនៅឡើយ ។ ថ្ងៃដែលសមត្ថកិច្ចទៅឆែកឆេរផ្ទះខ្លួននោះ ខ្លួនបានទៅលេងបងប្អូននៅខេត្តផ្សេង ។ ខ្លួនសំណូមពរសុំឱ្យតុលាការបើកផ្ទះឱ្យខ្លួនបានប្រើប្រាស់វិញ ។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីបានសួរដេញដោល និងពិនិត្យឯកសារក្នុងសំណុំរឿងឃើញថា ឆ្លងតាមការដេញដោលនាពេលសវនាការឃើញថា ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ពិតជាបានប្រព្រឹត្តអំពើ រក្សាទុក ដឹកជញ្ជូន ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទសម្អាតប្រាក់ ជនជាប់ចោទឈ្មោះ [redacted] ពន្លក ពិតជាបានប្រព្រឹត្តអំពើ រក្សាទុក ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន និងបទសម្អាតប្រាក់ និងជនជាប់ចោទឈ្មោះ [redacted] សួស្តី ហៅ តៅ ពិតជាបានប្រព្រឹត្តអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ពិតប្រាកដមែន ។ ហេតុដូច្នេះ តំណាងអយ្យការសុំតម្កល់សេចក្តីចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរទុកជាបានការទាំងស្រុង និងស្នើសុំតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-លោក [redacted] វី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការដេញដោលនាពេលសវនាការ និងពិនិត្យឯកសារក្នុងសំណុំរឿងឃើញថា ពាក់ព័ន្ធអង្គហេតុចោទប្រកាន់កូនក្តីខ្លួន ដោយយោងតាមអង្គហេតុថាបានប្រព្រឹត្តតាំងពីឆ្នាំ២០១៤ រហូតដល់ថ្ងៃឃាត់ខ្លួនឆ្នាំ២០២១ គឺមិនត្រឹមត្រូវទេ ដោយតាមការពិនិត្យចម្លើយដែលកូនក្តីខ្លួនបានឆ្លើយនៅតំណាក់កាលនគរបាលយុត្តិធម៌ កូនក្តីខ្លួនបានឆ្លើយ និងទទួលស្គាល់គឺបានប្រព្រឹត្តនៅពាក់កណ្តាលឆ្នាំ២០២០ ទាក់ទងបទចោទនេះ កូនក្តីខ្លួនបានសារភាពអស់ហើយ រួមទាំងបានសហការនៅជាមួយសមត្ថកិច្ច រហូតឈានទៅដល់ការឃាត់ខ្លួនជនល្មើសផ្សេងទៀតព្រមទាំងដកហូតបានថ្នាំញៀនជាច្រើន ។ តាមការសហការណ៍នេះផ្តល់ផលប្រយោជន៍ជាច្រើនដល់សង្គម គប្បីតុលាការពិចារណាលើចំណុចទាំងអស់នេះ និងស្នើសុំផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួនផង ។ ទាក់ទងនឹងផ្ទះ ខ្លួនបានដាក់ភស្តុតាងរួចហើយ ហើយកូនក្តីខ្លួនក៏ធ្លាប់បានបញ្ជាក់កន្លងមកហើយថា ផ្ទះនេះជារបស់ម្តាយរបស់កូនក្តីខ្លួនតាំងពីឆ្នាំ២០១៤ ហើយម្តាយរបស់កូនក្តីខ្លួនក៏បានឆ្លើយបញ្ជាក់ជូននាពេលសវនាការផងដែរ គឺគាត់លក់ដូរនៅទួលសង្កែ ដើម្បីទិញដីសង់ផ្ទះ មិនមែនកើតឡើងដោយការលក់ថ្នាំញៀននោះទេ ។ សំណូមពរឱ្យតុលាការអនុញ្ញាតបើកផ្ទះឱ្យឈ្មោះ [redacted] ប៊ុល វិញ ។

-លោក [redacted] ឡុងឌី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] សួស្តី បានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្លួនឈ្មោះ [redacted] ពន្លក បានឆ្លើយបដិសេធហើយថា មិនបានដឹងថាឥវ៉ាន់ឱ្យដឹកនោះជាគ្រឿងញៀននោះទេ ។ ដំបូងគឺឈ្មោះ [redacted] សួស្តី បានពឹងពាក់ឱ្យជួយដឹកត្រីងៀត ពីខេត្តក្រចេះមកភ្នំពេញ បានឱ្យប្រាក់ចំនួន ៥០០ $ ។ ប្រាក់ទាំងនេះត្រូវចំណាយលើការជួលឡាន ចាក់សាំង ការចាយវាយហូបចុកប៉ុណ្ណោះ ។ ខ្លួនស្នើសុំតុលាការលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួនឈ្មោះ [redacted] ពន្លក ។ ចំពោះកូនក្តីខ្លួនឈ្មោះ [redacted] សួស្តី បានសារភាពទទួលស្គាល់ពីកំហុសរួចហើយ ស្នើសុំឱ្យតុលាការផ្តល់ស្ថានសម្រាលដល់កូនក្តីខ្លួនឈ្មោះ [redacted] សួស្តី ។

## សម្ដីចុងក្រោយរបស់ជនជាប់ចោទ

65/7

-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ស្នើសុំតុលាការជួយបន្ធូរបន្ថយទោស ខ្លួនដឹងកំហុសហើយ ។

-ជនជាប់ចោទឈ្មោះ [redacted] ពន្លក ស្នើសុំតុលាការជួយរកយុត្តិធម៌ និងសម្រាលទោស ។

-ជនជាប់ចោទឈ្មោះ [redacted] សួស្ដី ស្នើសុំតុលាការជួយបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្ដាប់សម្ដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យកស្តុតាង និងពិចារណាលើសំណុំរឿងត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

១-កាលពីអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ នៅចំណុចរាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ពិតជាបានប្រព្រឹត្តបទល្មើស **រក្សាទុក ដឹកជញ្ជូន ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទសម្អាតប្រាក់** បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ មាត្រា ៧០ និងមាត្រា ៧១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ជនជាប់ចោទឈ្មោះ [redacted] ពន្លក ពិតជាបានប្រព្រឹត្តបទល្មើស **រក្សាទុក ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន និង បទសម្អាតប្រាក់** បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ មាត្រា ៧០ និងមាត្រា ៧១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងជនជាប់ចោទឈ្មោះ [redacted] សួស្ដី ហៅ ពៅ ពិតជាបានប្រព្រឹត្តបទល្មើស **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ដូចបានលើកឡើងក្នុងដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១០២១ "ហ" ជ.ជ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២២ ចេញដោយចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ មែន ។

២-តាមកំណត់ហេតុធ្វើតេស្ដបឋម និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១ របស់មន្ត្រីបច្ចេកទេសនៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀនបានបង្ហាញថា មន្ត្រីបច្ចេកទេសនៃការិយាល័យប្រឆាំងបទល្មើសគ្រឿងញៀនបានដំណើរការធ្វើតេស្ដបឋមដោយប្រើប្រាស់ឧបករណ៍ ម៉ាគីតេស្ដ និងម៉ាស៊ីនស្កេន TruNarc ព្រមទាំងវេចខ្ចប់ និងថ្លឹងដោយប្រើប្រាស់ជញ្ជីងម៉ាក VIBRA ។ ជាលទ្ធផលឃើញថា៖

-ក្រាមពណ៌សថ្លាចាប់យកនាពេលឃាត់ខ្លួនឈ្មោះ [redacted] ពិសិដ្ឋ មាន ទម្ងន់ ១០០ (មួយរយ) ក្រាម សង្ស័យមានវត្ថុមានសារធាតុញៀនឈ្មោះ **មេតំហ្វេតាមីន** ។

-ក្រាមពណ៌សថ្លាចាប់យកនាពេលឃាត់ខ្លួនឈ្មោះ [redacted] ពន្លក មានទម្ងន់ **២៩.៩៤០** (ម្ភៃប្រាំបួនពាន់ និងប្រាំបួនរយសែសិប) ក្រាម សង្ស័យមានវត្ថុមានសារធាតុញៀនឈ្មោះ **មេតំហ្វេតាមីន** ។

-ក្រាមពណ៌សថ្លាចាប់យកនាពេលឃាត់ខ្លួនឈ្មោះ [redacted] ពន្លក មានទម្ងន់ ១៩.៩៤៦,៦៦ (ដប់ប្រាំបួនពាន់ និងប្រាំបួនរយសែសិបប្រាំមួយ ក្បៀស ហុកសិបប្រាំមួយ) ក្រាម សង្ស័យមានវត្ថុមានសារធាតុញៀនឈ្មោះ **កេតាមីន** ។

-ក្រាមពណ៌សថ្លាចាប់យកនៅទីតាំងបន្ទប់ជួលរបស់ឈ្មោះ [redacted] ពិសិដ្ឋ មានទម្ងន់ ៣០០ (បីរយ) ក្រាម សង្ស័យមានវត្ថុមានសារធាតុញៀនប្រភេទមេតំហ្វេតាមីន ។

សរុបរួមវត្ថុចាប់យកសង្ស័យមានវត្ថុមានសារធាតុញៀនឈ្មោះ **មេតំហ្វេតាមីន** មានទម្ងន់ ៣០.៣៤០ ក្រាម (៣០ គីឡូក្រាម និង ៣៤០ ក្រាម) និង កេតាមីនមានទម្ងន់ **១៩.៩៤៦,៦៦ ក្រាម** (១៩ គីឡូក្រាម និង ៩៤៦,៦៦ ក្រាម) ។



Scanned with CamScanner

៣-តាមកំណត់ហេតុស្តីពីការទទួលស្គាល់វត្ថុតាង ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ របស់សមត្ថកិច្ចនគរបាលយុត្តិធម៌នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀនឃើញថា ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានទទួលស្គាល់ថា ក្រមព័ណ៌សថ្លាសង្ស័យមានវត្ថុមានសារធាតុញៀនមួយកញ្ចប់ដែលចាប់យកនាពេលឃាត់ខ្លួនជារបស់ខ្លួន ពិតប្រាកដមែន ។

៤-តាមកំណត់ហេតុស្តីពីការទទួលស្គាល់វត្ថុតាង ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២១ របស់សមត្ថកិច្ចនគរបាលយុត្តិធម៌នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀនឃើញថា ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានទទួលស្គាល់ថា ក្រមព័ណ៌សថ្លាសង្ស័យមានវត្ថុមានសារធាតុញៀនបីកញ្ចប់ ដែលសមត្ថកិច្ចចាប់យកបាននៅទីតាំងដីឡូតិ៍លេខ ១៣២៩ ក្រុមទី៨ ភូមិទួលថ្នាំ សង្កាត់ទួលសង្កែ២ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ជារបស់ខ្លួន ពិតប្រាកដមែន ។

៥-តាមកំណត់ហេតុស្តីពីការទទួលស្គាល់វត្ថុតាង ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ របស់សមត្ថកិច្ចនគរបាលយុត្តិធម៌នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀនឃើញថា ឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] ពន្លក បានទទួលស្គាល់ថា សំណាកចាប់យកនាពេលឃាត់ខ្លួនឈ្មោះ [redacted] ពន្លក ចំនួន ៣០ ដុំ ដែលសង្ស័យមានវត្ថុមានសារធាតុញៀនមេតំហ្វេតាមីន និងចំនួន ២០ ដុំ សង្ស័យមានវត្ថុមានសារធាតុញៀនប្រភេទកេតាមីន ពិតជារបស់ពួកគេ ពិតមែន ។

៦-តាមរបាយការណ៍លេខ ៣២៩៧១/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍ ស្តីពីលទ្ធផលកោសលវិច័យគ្រឿងញៀន លើសំណាកដែលចាប់យកនាពេលឃាត់ខ្លួនឈ្មោះ [redacted] ពិសិដ្ឋ និងនាពេលឆែកឆេរទីតាំងបន្ទប់ជួលរបស់ឈ្មោះ [redacted] ពិសិដ្ឋ បានបង្ហាញថា សំណាកជាគ្រឿងញៀនប្រភេទ មេតំហ្វេតាមីន (ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧៨,១០% នៃទម្ងន់សរុប ដែលស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ហេតុដូចនេះ ទម្ងន់សរុបនៃសារធាតុញៀនមានចំនួន ៣១២,៤ ក្រាម (បីរយដប់ពីរក្បៀសបួនក្រាម) (៤០០ ក្រាម X ៧៨,១០/ ១០០) ។

៧-តាមរបាយការណ៍លេខ ៣២៩៧១/២១ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១ របស់មន្ទីរពិសោធន៍ លើសំណាកដែលចាប់យកនាពេលឃាត់ខ្លួនឈ្មោះ [redacted] ពន្លក ស្តីពីលទ្ធផលកោសលវិច័យគ្រឿងញៀន បានបង្ហាញថា៖ សំណាកទីមួយជាគ្រឿងញៀនប្រភេទ មេតំហ្វេតាមីន (ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកម្រិតភាពសុទ្ធ ៧៨,១០% នៃទម្ងន់សរុប ដែលស្ថិតក្នុងតារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ហេតុដូចនេះ ទម្ងន់សារធាតុញៀន **មេតំហ្វេតាមីន** សរុបមានចំនួន **២៣.៣៨៣,១៤** (ម្ភៃបីពាន់ និងបីរយប៉ែតសិបបី ក្បៀសដប់បួន) **ក្រាម** (២៩.៩៤០ ក្រាម X ៧៨,១០/ ១០០) និងសំណាកទីពីរជាគ្រឿងញៀនប្រភេទ **កេតាមីន** ដែលមានកម្រិតភាពសុទ្ធ ៦៥,៩១% នៃទម្ងន់សរុប ដែលស្ថិតក្នុងតារាងទី៣ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ហេតុដូចនេះ ទម្ងន់សារធាតុញៀន **កេតាមីន** សរុបមានចំនួន **១៣,១៤៦.៨៤** (ដប់បីពាន់ និងមួយរយសែសិបប្រាំមួយ ក្បៀសប៉ែតសិបបួន) **ក្រាម** (១៩.៩៤៦,៦៦ ក្រាម X ៦៥,៩១/១០០) ។

៨-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានទទួលស្គាល់ថាជនជាប់ចោទពិតជាបានធ្វើសកម្មភាព រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ព្រមទាំងបានធ្វើសកម្មភាព សម្អាតប្រាក់ ពិតប្រាកដមែន ។ ជនជាប់ចោទគ្រាន់តែបដិសេធថា កម្រៃដែលជនជាប់ចោទបានទទួលពីបទល្មើសគ្រឿងញៀន ជនជាប់ចោទមិនបានយកទៅទិញដី និងសង់ផ្ទះនៅក្នុងសង្កាត់ក្រាំងធ្នង់នោះទេ ហើយប្រាក់ទាំងនោះជនជាប់ចោទបានចំណាយទិញម៉ូតូចំនួន ០១ គ្រឿង និងផ្គត់ផ្គង់ប្រពន្ធកូន ព្រមទាំងចំណាយផ្ទាល់ខ្លួនប៉ុណ្ណោះ ។



Scanned with CamScanner

៩-ជនជាប់ចោទឈ្មោះ [redacted] ពន្លក បានបដិសេធថា ជនជាប់ចោទមិនបានដឹងថា វត្ថុដែលជនជាប់ចោទដឹក យកទៅប្រគល់ជូនឈ្មោះ [redacted] ពិសិដ្ឋ មានលាក់ទុកគ្រឿងញៀននោះទេ ។ ជនជាប់ចោទគ្រាន់តែទៅទទួលដឹកទំនិញពីខេត្តក្រចេះមកភ្នំពេញតាមការបញ្ជារបស់ឈ្មោះ [redacted] សួស្តី ជាថ្នូរនឹងការផ្តល់កម្រៃសេវាចំនួន ៣.០០០ ដុល្លារអាមេរិក ។

១០-ជនជាប់ចោទឈ្មោះ [redacted] សួស្តី បានទទួលស្គាល់ថា ជនជាប់ចោទពិតជាបានណែនាំឱ្យឈ្មោះ [redacted] ពន្លក ដឹកគ្រឿងញៀនពីខេត្តក្រចេះមកភ្នំពេញឱ្យឈ្មោះ [redacted] ពិសិដ្ឋ មែន ដោយសន្យាផ្តល់កម្រៃសេវាចំនួន ៣.០០០ ដុល្លារអាមេរិក ទៅឈ្មោះ [redacted] ពន្លក ។

១១-តាមរបាយការណ៍សមត្ថកិច្ច ចម្លើយសារភាពរបស់ជនជាប់ចោទ ក៏ដូចជាភស្តុតាងដែលមានក្នុងសំណុំរឿងមានភាពស៊ីសង្វាក់ក្នុងការបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] សួស្តី និងឈ្មោះ [redacted] ពិសិដ្ឋ ពិតជាមានការព្រមព្រៀងដោយផ្ទាល់ធ្វើសកម្មភាព **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ពិតប្រាកដមែន ។

១២-តាមរបាយការណ៍សមត្ថកិច្ច ចម្លើយសារភាពរបស់ជនជាប់ចោទ ក៏ដូចជាភស្តុតាងដែលមានក្នុងសំណុំរឿង មានភាពស៊ីសង្វាក់ក្នុងការបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] ពិសិដ្ឋ ពិតជាបានធ្វើសកម្មភាព **រក្សាទុក** និង **ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន** ពិតប្រាកដមែន ។ បើទោះបីជាជនជាប់ចោទឈ្មោះ [redacted] ពន្លក បានបដិសេធថា ខ្លួនមិនបានដឹងថា វត្ថុដែលខ្លួនរក្សាទុក និងដឹកជញ្ជូននោះមានផ្ទុកសារធាតុញៀន តុលាការយល់ឃើញថា គ្រាន់តែជាការឆ្លើយដោះសារដើម្បីរួចផុតពីការទទួលខុសត្រូវប៉ុណ្ណោះ ។ ជនជាប់ចោទឈ្មោះ [redacted] ពន្លក ស្ថិតក្នុងស្ថានភាពដែលអាចនឹងដឹងថា វត្ថុដែលជនជាប់ចោទឈ្មោះ [redacted] សួស្តី បានណែនាំឱ្យជនជាប់ចោទរក្សាទុក និងដឹកជញ្ជូនទៅឱ្យឈ្មោះ [redacted] ពិសិដ្ឋ ជាសារធាតុញៀន ។

១៣-តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ការកាន់កាប់ ការលាក់ទុក សន្និធិ និងសកម្មភាពប្រហាក់ប្រហែលផ្សេងទៀតដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ។

១៤-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] ពន្លក ដែលបានធ្វើសកម្មភាពកាន់កាប់ និងលាក់ទុកដោយខុសច្បាប់នូវសារធាតុញៀន គឺជាបទល្មើស **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** តាមមាត្រា ៤០ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៥-តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី២ ការបញ្ជូនតាមគ្រប់រូបភាពដែលនាំឱ្យមានការផ្លាស់ទី ពីទីកន្លែងមួយទៅទីកន្លែងមួយទៀត ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬពីប្រទេសមួយទៅប្រទេសមួយទៀតដោយខុសច្បាប់នូវសារធាតុញៀនជាអាទិ៍ តាមរយៈការផ្ញើ ការធ្វើចរាចរ ការនាំចូល ឬការនាំចេញ គឺជា **អំពើដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន** ។

១៦-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] ពន្លក ដែលបានធ្វើសកម្មភាពផ្លាស់ទីសារធាតុញៀនពីកន្លែងមួយទៅកន្លែងមួយគឺជាបទល្មើស **ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន** តាមមាត្រា ៤០ កថាខណ្ឌទី២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៧-តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ។

១៨-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] សួស្តី បានដែលបានព្រមព្រៀងដោយផ្ទាល់ធ្វើសកម្មភាពលក់ និងផ្តល់សម្រាប់ការលក់ដោយខុសច្បាប់នូវសារធាតុញៀន គឺជាបទល្មើស **ជួញដូរដោយខុសច្បាប់នូវ**



Scanned with CamScanner

សារធាតុញៀន តាមមាត្រា ៤០ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១៩-តាមរបាយការណ៍ លេខ ០៧៥ ឆ.ត ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ របស់នាយកដ្ឋានប្រឆាំងបទល្មើសគ្រឿងញៀន បានបង្ហាញថា ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ជាមុខសញ្ញាចាស់ ដែលបានធ្វើសកម្មភាពជួញដូរគ្រឿងញៀនតាំងពីមុនឆ្នាំ ២០១៤ ។ ជាក់ស្តែងយោងតាមរបាយការណ៍ព័ត៌មានពីមណ្ឌលអប់រំកែប្រែទី១ (ម១) ក៏បានបញ្ជាក់ជូនផងដែរថា ឈ្មោះនេះធ្លាប់ជាប់ឃុំនៅ ម១ កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤ ដល់ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៤ ពីបទ **ជួញដូរដោយខុសច្បាប់នូវគ្រឿងញៀន** ។ ចំពោះទ្រព្យសម្បត្តិរបស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ដែលបានបង្កកឆ្លងតាមការស៊ើបអង្កេតឃើញថា ជាទ្រព្យសម្បត្តិបានមកពីផលនៃបទល្មើសគ្រឿងញៀន ។

២០-បើទោះបីជាជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានបដិសេធថា អចលនវត្ថុដីឡូត៍លេខ D2 ទំហំ ៧០ ម៉ែត្រការ៉េ ស្ថិតនៅភូមិដាងទង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ សម្គាល់ដោយលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ២៥៤១ លប.កព្រ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ជាកម្មសិទ្ធិរបស់ម្តាយជនជាប់ចោទ ហើយមិនមែនជាទ្រព្យសម្បត្តិដែលកើតចេញពីផលនៃបទល្មើសក៏ដោយ ក៏មិនអាចឱ្យតុលាការជឿជាក់បានឡើយ ។ ជាក់ស្តែងជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយសារភាពនៅសមត្ថកិច្ចនគរបាលយុត្តិធម៌ថា ដីឡូត៍លេខ ដេ២ និងផ្ទះនៅលើដីឡូត៍គឺជនជាប់ចោទបានចំណាយប្រាក់ដែលបានមកពីការដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀនដើម្បីទិញ និងសាងសង់ផ្ទះ ។ បន្ថែមពីលើនេះទៀត អចលនវត្ថុនេះជាទីតាំងដែលជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ រស់នៅ និងកាន់កាប់ជាក់ស្តែង មិនមែនឈ្មោះ [redacted] ប៉ុល ដែលត្រូវជាម្តាយបង្កើតរបស់ឈ្មោះ [redacted] ពិសិដ្ឋ កាន់កាប់នោះទេ ។ ហេតុដូចនេះ តុលាការយល់ឃើញថា ឈ្មោះ [redacted] ប៉ុល គ្រាន់តែជាតតិយជនដែលឈ្មោះ [redacted] ពិសិដ្ឋ ប្រើប្រាស់ដើម្បីឱ្យឈរឈ្មោះលើលិខិតស្នាមនានាដើម្បីលាក់បំបាំងនូវប្រភពមិនស្របច្បាប់នៃទ្រព្យសម្បត្តិរបស់ខ្លួន តែប៉ុណ្ណោះ ។ ចំណែក ជនជាប់ចោទឈ្មោះ [redacted] ពន្លក ក៏ទទួលបាននូវផលប្រយោជន៍ដែលកើតចេញពីបទល្មើស ហើយបានចំណាយនូវប្រាក់ដែលទទួលបានដើម្បីទិញនូវរថយន្តមួយគ្រឿង ។ ដើម្បីលាក់បំបាំងនូវប្រភពមិនស្របច្បាប់នៃទ្រព្យសម្បត្តិនេះ ជនជាប់ចោទបានចុះបញ្ជីនូវរថយន្តនេះក្រោមកម្មសិទ្ធិរបស់តតិយជន ។

២១-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] ពន្លក ដែលបានធ្វើសកម្មភាពបំប្លែងនូវប្រាក់ដោយដឹងថា ប្រាក់ទាំងនោះទទួលបានពីបទល្មើសគ្រឿងញៀន ក្នុងគោលបំណងបិទបាំងប្រភពមិនស្របច្បាប់នូវទ្រព្យសម្បត្តិទាំងអស់នោះ ជាបទល្មើសសម្អាតប្រាក់ ។ ជារួម អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ និងឈ្មោះ [redacted] ពន្លក ដែលបានលើកឡើង បានប្រព្រឹត្តផ្ទុយនឹងបញ្ញត្តិមាត្រា ៧០ **កថាខណ្ឌទី១** នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលបានបញ្ញត្តិអំពីនិយមន័យនៃការសម្អាតប្រាក់ថា៖

*"ការបំប្លែង ការផ្ទេរ ការធ្វើលទ្ធកម្ម ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិ ការបិទបាំង ឬការក្លែងសភាវៈពិត ប្រភព ទីតាំង សិទ្ធិទាត់ចែង ចលនា កម្មសិទ្ធិ ឬសិទ្ធិលើទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិនេះជាផលនៃបទល្មើសដែលមានចែងចាប់ពីមាត្រា ៣៩ ដល់មាត្រា ៤២ ពីមាត្រា ៤៧ ដល់មាត្រា ៥០ មាត្រា ៥៤ និងមាត្រា ៥៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ក្នុងគោលបំណងបិទបាំង ឬក្លែងប្រភពដើមមិនស្របច្បាប់នៃទ្រព្យសម្បត្តិទាំងនេះ ឬជួយបុគ្គលណាដែលបានពាក់ព័ន្ធក្នុងបទល្មើស ដើម្បីឱ្យបុគ្គលនោះគេចផុតពីផលវិបាកតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន គឺជាអំពើសម្អាតប្រាក់ ។"*

២២-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ឈ្មោះ [redacted] ពន្លក និងឈ្មោះ [redacted] សួស្តី ហៅ តៅ នាពេលប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពដែលអាចយល់ដឹងអំពីលទ្ធផលតាមផ្លូវច្បាប់ ចំពោះអំពើរបស់ខ្លួនមានសមត្ថភាពគ្រប់គ្រាន់



Scanned with CamScanner

ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌ ។

**២៣**-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការមានហេតុផលគ្រប់គ្រាន់ គប្បីតុលាការលើកយកមកពិចារណា។

**២៤**-សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ មិនមានសំអាងគ្រប់គ្រាន់មិនអាចឱ្យតុលាការជឿជាក់បានឡើយ ។

**២៥**-មានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទ ឈ្មោះ [redacted] **ពិសិដ្ឋ** ពីបទ **រក្សាទុក ដឹកជញ្ជូន ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទសម្អាតប្រាក់** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានថែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ មាត្រា ៧០ និងមាត្រា ៧១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

**២៦**-មានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទ ឈ្មោះ [redacted] **ពន្លក** ពីបទ **រក្សាទុក ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន** និង **បទសម្អាតប្រាក់** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានថែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ មាត្រា ៧០ និងមាត្រា ៧១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

**២៧**-មានពិរុទ្ធគ្រប់គ្រាន់លើជនជាប់ចោទ ឈ្មោះ [redacted] **សួស្ដី** ហៅ **ពៅ** ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានថែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

**២៨**-ទ្រព្យសម្បត្តិ ក-ដីឡូត៍លេខ D2 ទំហំ ៧០ម² មានទីតាំងស្ថិតនៅភូមិជាងទង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ សម្គាល់ដោយលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ២៥៤១ លប.កព្រ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ចេញសាលាខណ្ឌសែនសុខ ខ-ម៉ូតូម៉ាក HONDA PCX 150 ពណ៌ស ពាក់ស្លាកលេខស្វាយរៀង 1P-9730 ចំនួន ០១ គ្រឿង និង គ-រថយន្តម៉ាក TOYATA CAMRY ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ 2T-6441 ចំនួន ០១ គ្រឿង ដែលត្រូវបានចៅក្រមស៊ើបសួរសម្រេចបង្កកតាមដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ ១៣ "ធ១" ដ.ប.ទ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២១ ត្រូវបានរកឃើញថា ជាទ្រព្យសម្បត្តិដែលកើតចេញពីផលនៃបទល្មើស គប្បីតុលាការសម្រេចរឹបអូស ។ យោងតាមបញ្ញត្តិមាត្រា ១២២ នៃក្រមរដ្ឋប្បវេណី ឃើញថា ផ្ទះដែលបានជនជាប់ចោទ ឈ្មោះ [redacted] **ពិសិដ្ឋ** បានសាងសង់នៅលើដីឡូត៍លេខ D2 ខាងលើត្រូវបានក្លាយជាសមាសភាពនៃដី ហេតុដូចនេះការសម្រេចរឹបអូសដីឡូត៍លេខ D2 ខាងលើក៏ត្រូវបានរួមបញ្ចូលផងដែរនៅផ្ទះដែលបានសាងសង់នៅលើដីនេះ ។

**២៩**-តាមកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១២២៣ រ.ប.គ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២១ របស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ឃើញថា វត្ថុចាប់យកដែលដកហូតពីជនជាប់ចោទផ្សេងទៀតរួមមាន៖ក-វត្ថុចាប់យកមានផ្ទុកសារធាតុញៀនទម្ងន់ ៥០.២៨៦,៦៦ (ហាសិបពាន់ និងពីររយប៉ែតសិបប្រាំមួយ ក្បៀសហុកសិបប្រាំមួយ) ក្រាម ដែលបានរក្សាទុកក្នុងហិបដែកចំនួន ០១ ពណ៌ទឹកប្រាក់ ខ-កញ្ចប់ថង់ប្លាស្ទិកច្រកគ្រឿងញៀនពណ៌ខៀវ ១៦ កញ្ចប់ និង ០២ កំណាត់ គ-ថង់ប្លាស្ទិកសថ្លាចំនួន ០៣ កញ្ចប់ ឃ-ដាវកែច្នៃចំនួន ០១ ដើម ឃ-សម្ភារៈសម្រាប់ប្រើប្រាស់គ្រឿងញៀន ថង់ក្រដាសពណ៌ផ្កាឈូក និងថង់ក្រណាត់មួយចំនួន ង-សៀវភៅសរសេរម៉ាកស៊្រីន ងួន (SNG-70SM) ១៤០ ទំព័រ ០១ ក្បាល ច-សៀវភៅសរសេរគ្មានក្រប ០១ ក្បាល ជ-កូនសៀវភៅលេខទូរស័ព្ទ ០១ ក្បាល ឈ-ក្រដាសកត់ត្រាលេខទូរស័ព្ទមួយចំនួន ញ-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៥៤៤២៦៤ (០១) ថតចម្លង ដ-ប័ណ្ណសម្គាល់ទោចក្រយានយន្តចំនួន ០១ (ស្វាយរៀង 1P-9730) ថតចម្លង ឋ-ស្លាកលេខម៉ូ



Scanned with CamScanner

គួចំនួន ០១ (ភ្នំពេញ 1GQ-0844) (ភ្នំពេញ 1HS-8441) ខ-ទូរស័ព្ទ ០១ គ្រឿង ម៉ាក OPPO ពណ៌ខៀវ (IMEI 867218050712116) ឍ-ទូរស័ព្ទចំនួន ០២ គ្រឿង SAMSUNG (IMY48BJ700KKU1ARK2) និង OPPO (IMEI 862627059728938) ជាទ្រព្យសម្បត្តិដែលត្រូវបានកាន់កាប់ដោយខុសច្បាប់ ឬជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីសម្រេចរឹបអូស ។

៣០-ជនជាប់ចោទឈ្មោះ[redacted] ពន្លក បានផ្ដួលប្រព្រឹត្តបទល្មើសឧក្រិដ្ឋនេះដោយសារការខ្វះការពិចារណា ឱ្យបានគ្រប់ជ្រុងជ្រោយ និងការលោភលន់មួយគ្រាទើបធ្លាក់ក្រោមការអូសទាញរបស់ឈ្មោះ [redacted] សួស្តី ដែលជាមេខ្លោងនៃសកម្មភាពល្មើស ។ យោងតាមរបាយការណ៍របស់សមត្ថកិច្ចនគរបាលនៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀនក៏បានបង្ហាញផងដែរថា ឈ្មោះ [redacted] ពន្លក ពុំមានប្រវត្តិពាក់ព័ន្ធទៅនឹងការប្រព្រឹត្តបទល្មើសណាមួយពីមុនមកនោះទេ ។ ហេតុដូចនេះ គប្បីតុលាការផ្ដល់ស្ថានសម្រាលដល់ជនជាប់ចោទឈ្មោះ[redacted]ពន្លក ។

៣១-ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ បានឆ្លើយសារភាពទទួលស្គាល់នូវទោសកំហុសរបស់ខ្លួនចំពោះមុខតុលាការមានចេតនាកែខ្លួនជាបុគ្គលល្អក្នុងសង្គម ។ ជាងនេះទៀត ជនជាប់ចោទឈ្មោះ [redacted]ពិសិដ្ឋ ក៏ពុំមែនជាមេខ្លោងនៅក្នុងសកម្មភាពឧក្រិដ្ឋនេះផងដែរ គប្បីតុលាការផ្ដល់ស្ថានសម្រាលដល់ជនជាប់ចោទឈ្មោះ [redacted] ពិសិដ្ឋ ។

<u>**ហេតុដូច្នេះ វិនិច្ឆ័យសេចក្ដី**</u>

**១-ផ្ដន្ទាទោស** ឈ្មោះ [redacted] **ពន្លក** ភេទប្រុស អាយុ ៣១ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់ ២៣ (ម្ភៃបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០.០០០.០០០ (**សែសិបលាន**) រៀល ពីបទ **រក្សាទុក ដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន និងបទសម្អាតប្រាក់** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ មាត្រា ៧០ និងមាត្រា ៧១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

**២-ផ្ដន្ទាទោស** ឈ្មោះ [redacted] **ពិសិដ្ឋ** ភេទប្រុស អាយុ ៣៧ឆ្នាំ ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់ ២៥ (ម្ភៃប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៦០.០០០.០០០ (**ហុកសិបលាន**) រៀល ពីបទ **រក្សាទុក ដឹកជញ្ជូន ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទសម្អាតប្រាក់** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ មាត្រា ៧០ និងមាត្រា ៧១ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៣-ផ្ដន្ទាទោស** ឈ្មោះ [redacted] **សួស្ដី** ហៅ ពៅ ភេទប្រុស កើតឆ្នាំ១៩៨២ ដែលមានអត្តសញ្ញាណខាងលើ ដាក់ពន្ធនាគារកំណត់ ៣០ (**សាមសិប**) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០០ (**ប៉ែតសិបលាន**) រៀល ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលអំឡុងឆ្នាំ២០១៤ រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

**៤-រឹបអូសវត្ថុចាប់យក និងទ្រព្យសម្បត្តិដូចខាងក្រោម៖**

-ដីឡូតិ៍លេខ D2 ទំហំ ៧០ម² មានទីតាំងស្ថិតនៅភូមិជាងទង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ សម្គាល់ដោយលិខិតផ្ទេរសិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី និងផ្ទះសម្បែងលេខ ២៥៤១ លប.កព្រ ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ចេញដោយសាលាខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

-ម៉ូតូម៉ាក HONDA PCX 150 ពណ៌ស ចំនួន ០១ គ្រឿង ពាក់ស្លាកលេខស្វាយរៀង 1P-9730 ។

-រថយន្តម៉ាក TOYATA CAMRY ពណ៌ខ្មៅ ពាក់ស្លាកលេខភ្នំពេញ 2T-6441 ។

-ទូរស័ព្ទម៉ាក OPPO ពណ៌ខៀវ (IMEI 867218050712116) ០១ គ្រឿង ។

-ទូរស័ព្ទម៉ាក SAMSUNG (IMY48BJ700KKU1ARK2) ចំនួន ០១ គ្រឿង ។



Scanned with CamScanner

-ទូរស័ព្ទម៉ាក OPPO (IMEI 862627059728938) ចំនួន ០១ គ្រឿង ។

-ក្រាមពណ៌សថ្លាមានផ្ទុកសារធាតុញៀន ប្រភេទមេតំហ្វេតាមីន នៅសល់ពីការដកហូតធ្វើកោសលវិច័យ (ទម្ងន់មុនពេលដកហូត ១០០ ក្រាម) ។

-ក្រាមពណ៌សថ្លាមានផ្ទុកសារធាតុញៀន ប្រភេទមេតំហ្វេតាមីន នៅសល់ពីការដកហូតធ្វើកោសលវិច័យ (ទម្ងន់មុនពេលដកហូត ២៩៩៤០ ក្រាម) ។

-ក្រាមពណ៌សថ្លាមានផ្ទុកសារធាតុញៀន ប្រភេទកេតាមីន នៅសល់ពីការដកហូតធ្វើកោសលវិច័យ (ទម្ងន់មុនពេលដកហូត ១៩៩៤៦.៦៦ ក្រាម) ។

-ក្រាមពណ៌សថ្លាមានផ្ទុកសារធាតុញៀន ប្រភេទមេតំហ្វេតាមីន នៅសល់ពីការដកហូតធ្វើកោសលវិច័យ (ទម្ងន់មុនពេលដកហូត ៣០០ ក្រាម) ។

-កញ្ចប់ថង់ប្លាស្ទិកច្រកគ្រឿងញៀនពណ៌ខៀវ ១៦ កញ្ចប់ និង ០២ កំណាត់ ។

-ថង់ប្លាស្ទិកសថ្លាចំនួន ០៣ កញ្ចប់ ។

-ដាវកែច្នៃ ០១ ដើម ។

-សម្ភារៈសម្រាប់ប្រើប្រាស់គ្រឿងញៀន ថង់ក្រដាសពណ៌ផ្កាឈូក និងថង់ក្រណាត់មួយចំនួន ។

-សៀវភៅសរសេរម៉ាក [redacted] ដួន (SNG-70SM) ១៥០ ទំព័រ ០១ ក្បាល ។

-សៀវភៅសរសេរគ្មានក្រប ០១ ក្បាល ។

-កូនសៀវភៅលេខទូរស័ព្ទ ០១ ក្បាល ។

-ក្រដាសកត់ត្រាលេខទូរស័ព្ទមួយចំនួន ។

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១០៥៤៤២៦៤ (០១) ថតចម្លង ។

-ប័ណ្ណសម្គាល់ទោចក្រយានយន្តចំនួន ០១ (ស្លាយរៀង 1P-9730) ថតចម្លង ។

-ស្លាកលេខម៉ូតូចំនួន ០២ (ភ្នំពេញ 1GQ-0844) (ភ្នំពេញ 1HS-8441) ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted]តិសិដ្ឋ ឈ្មោះ [redacted]ពន្លក និងឈ្មោះ [redacted]បូស្តី ហៅ ពៅ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted] |

**បានឃើញ**

ថ្ងៃពុធ ០៦រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃពុធ ០៦រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner